ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY


## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិតរបស់ ក្រុមហ៊ុន អេប្រាធី ហ្វូដ (ខេមបូឌា)

# EFFICIENCY OF THE PRODUCTION PROCESS OF APRATI FOODS (CAMBODIA) LTD

## ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

## ប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិតរបស់ ក្រុមហ៊ុន អេប្រាធី ហ្វូដ (ខេមបូឌា)

## EFFICIENCY OF THE PRODUCTION PROCESS OF APRATI FOODS (CAMBODIA) LTD

**គ្រូណែនាំ៖ កុយ សុធី**

**ជំនាញ គណនេយ្យ**

**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទ៖ ប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិតរបស់ក្រុមហ៊ុន**
**អេប្រាធី ហ្វ៊ូដ (ខេមបូឌា)**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

កុយ សុធី

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយកមជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករងមជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ សាកលវិទ្យាល័យ វ៉ាន់ដា អស់រយៈពេល៤ឆ្នាំ សិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេស ក្រុមយើងខ្ញុំបានយល់ច្បាស់ថា ជំនាញគណនេយ្យ គឺជាជំនាញមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការគណនេយ្យដូចគ្នា។ ដោយ ឡែកដើម្បីឱ្យការសិក្សារបស់និស្សិត កាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញ សំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យបានយល់ច្បាស់ពីការ អនុវត្តការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រម ទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុង ន័យឆ្លើយតប ឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុម យើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការ សិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **«ប្រសិទ្ធភាព នៃដំណើរការផលិតរបស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)»** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រង ក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការ ធ្វើម៉ាឃីតធីង។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណាមួយនេះឡើង នឹងបានចូលរួមចំណែកមួយក្នុងការ ស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានគោលបំណងសិក្សាស្វែងយល់ ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអាន ទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹង ទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



វណ្ណា វីរៈយុទ្ធ
ID: B22/2053



រិទ្ធ ជាតាំង
ID: B22/1117



ឌី សុភ័ក្រ្តវត្តី
ID: B22/2024



វន ស្រីណាត
ID: B22/2029



រុន សុម៉ាវត្តី
ID: B22/2023

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យ វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ដាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការ ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ **កុយ សុធី** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតដល់ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទស្តីអំពី «ប្រសិទ្ធភាពនៃដំណើរការផលិតរបស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)» នេះគឺពិតជាស្នាដៃមួយរបស់ក្រុមខ្ញុំបាទ នាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលដែលទាក់ទងទៅនឹងការស្រាវជ្រាវ ដែលបានលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃសៅរ៍ ៤កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

ថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



រិទ្ធ ជាកាំង

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

បច្ចុប្បន្ន សេដ្ឋកិច្ចពិភពលោកកំពុងតែមានការអភិវឌ្ឍទៅមុខយ៉ាងគួរឱ្យកត់សម្គាល់។ ជាពិសេសទៅលើវិស័យផលិតកម្ម។ វិស័យនេះ កំពុងបានឈានទៅមុខយ៉ាងខ្លាំងក្នុងការអភិវឌ្ឍខឿនសេដ្ឋកិច្ចនៃប្រទេសជាតិណាមួយឱ្យរីកចម្រើនទៅមុខបាន។ ដូច្នេះហើយ ការគ្រប់គ្រងដំណើរផលិតឱ្យមានប្រសិទ្ធភាព គឺជាគ្រឹះមួយយ៉ាងសំខាន់សម្រាប់សហគ្រាស ឬអង្គភាពអាជីវកម្មមួយ ដើម្បីអាចជួយពង្រឹង និងពង្រីកមិនថាតែប្រាក់ចំណេញ និងសកម្មភាពអាជីវកម្មនោះទេ។ ហេតុដូច្នេះហើយ ទើបក្រុមយើងខ្ញុំបានខិតខំសិក្សាស្រាវជ្រាវចងក្រងជារបាយការណ៍មួយផ្នែក ដែលមានខ្លឹមសារទាក់ទងនឹងប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិតរបស់ក្រុមហ៊ុន អេប្រាជី ហ្វ៊ូដ (ខេមបូឌា) ដើម្បីផ្តល់ជូនចំណេះដឹង និងការយល់ដឹងកាន់តែច្បាស់អំពីការគ្រប់គ្រងដំណើរការផលិតឱ្យមានប្រសិទ្ធភាពរបស់អង្គភាពអាជីវកម្មនៅក្នុងប្រទេសកម្ពុជា។

ក្រៅពីនេះទៅទៀត ក្រុមហ៊ុន អេប្រាជី ហ្វ៊ូដ (ខេមបូឌា) ក៏បានបន្តពង្រឹង និងអភិវឌ្ឍនូវការគ្រប់គ្រងប្រព័ន្ធផលិតកម្មរបស់ខ្លួន ដើម្បីឱ្យដើរទាន់យុគសម័យទំនើបនៅក្នុងវិស័យផលិតកម្មនេះបាន ដែលមានជាច្រើនចំណុចដូចជា ការបន្តអភិវឌ្ឍសមត្ថភាពបុគ្គលិកនិងកម្មករក្នុងផ្នែកផលិតកម្ម ការប្រើប្រាស់ប្រព័ន្ធ Software ក្នុងការគ្រប់គ្រងវត្ថុធាតុដើមនិងដំណើរការផលិត និងចំណុចសំខាន់ៗមួយចំនួនទៀតដូចជា ការជ្រើសរើសវត្ថុធាតុដើម ដើម្បីយកមកផលិត ការរៀបចំទុកដាក់វត្ថុធាតុដើម សម្រាប់ដំណើរការផលិតក៏បានបែងចែកទៅជាច្រើនដំណាក់កាល ដែលគោរពទៅតាមស្តង់ដាសុវត្ថិភាពចំណីអាហារ បន្ទាប់មកត្រូវឆ្លងកាត់ដំណើរការវេចខ្ចប់យ៉ាងមានអនាម័យ បន្ទាប់មកទៀតត្រូវឆ្លងការត្រួតពិនិត្យគុណភាពផលិតផល ដើម្បីធានានូវគុណភាពផលិតផលសម្រេច រួចហើយក៏បន្តយកទៅឃ្លាំងស្តុកទុកផលិតផលសម្រេច ដើម្បីនាំចេញទៅលក់ ទាំងទីផ្សារក្នុងស្រុក ជាពិសេសនាំចេញទៅក្រៅប្រទេសថែមទៀតផង ។

ដោយឆ្លងតាមការសិក្សាស្រាវជ្រាវខាងលើនេះ យើងអាចសន្និដ្ឋានបានថា ក្រុនហ៊ុនអេប្រាជី ហ្វ៊ូដ (ខេមបូឌា) ពិតជាមាននីតិវិធី និងវិធីសាស្រ្តយ៉ាងច្បាស់លាស់ណាស់នៅក្នុងការគ្រប់គ្រងដំណើរការផលិតរបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងអភិវឌ្ឍសមត្ថភាពយ៉ាងគួរឱ្យកត់សម្គាល់។ ការគ្រប់គ្រងដំណើរការផលិតឱ្យស្របទៅតាមស្តង់ដាសុវត្ថិភាពចំណីអាហារ ការរក្សាអនាម័យក្នុងការផលិត ជាពិសេសការយកចិត្តទុកដាក់នៅគ្រប់ជំហាន និងដំណាក់កាលទាំងអស់ ចាប់តាំងពីការជ្រើសរើសវត្ថុធាតុដើម រហូតដល់ផលិតបានទៅជាផលិតផលសម្រេច។ បច្ចុប្បន្ននេះ ក្រុមហ៊ុន អេប្រាជី ហ្វ៊ូដ (ខេមបូឌា) មិនត្រឹមតែផ្គត់ផ្គង់ផលិតផលរបស់ខ្លួននៅក្នុងស្រុកនោះទេ ថែមទាំងបាននាំចេញទៅក្រៅប្រទេសថែមទៀតផង។

# មាតិកា

ទំព័រ

អារម្ភកថា ..... i
របនាសម្ព័ន្ធក្រុម ..... ii
សេចក្តីថ្លែងអំណរគុណ ..... iii
អំណះអំណាង ..... iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ..... v
មាតិកា ..... vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ..... ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ..... ១
១.៣ គោលបំណងនៃការស្រាវជ្រាវ ..... ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ..... ២
១.៤.១ ទំហំដែនកំណត់ ..... ២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ..... ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ..... ២
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ..... ៣
១.៧ របនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៤

## ជំពូកទី២
## ប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិតរបស់ក្រុមហ៊ុនផលិតកម្ម

២.១ លក្ខណៈទូទៅនៃប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិត ..... ៥
២.១.១ និយមន័យ ..... ៥
២.១.២ ប្រវត្តិប្រសិទ្ធភាព និងការគ្រប់គ្រង ..... ៥
២.១.៣ ទ្រឹស្តីប្រសិទ្ធភាព និងការគ្រប់គ្រង ..... ៦
២.១.៤ ប្រភេទនៃការគ្រប់គ្រង ..... ៧
២.២ យុទ្ធសាស្ត្រក្នុងការគ្រប់គ្រង ..... ៨
២.២.១ និយមន័យយុទ្ធសាស្ត្រការគ្រប់គ្រង ..... ៨
២.២.២ ប្រវត្តិនៃយុទ្ធសាស្ត្រ ..... ៨
២.២.៣ ទ្រឹស្តីនៃយុទ្ធសាស្ត្រ ..... ៩

២.២.៤ ប្រភេទនៃយុទ្ធសាស្ត្រនៃការគ្រប់គ្រង ....................១០
២.៣ អត្ថប្រយោជន៍នៃការគ្រប់គ្រងការផលិត ....................១១
២.៣.១ និយមន័យ ....................១១
២.៣.២ ប្រវត្តិនៃការគ្រប់គ្រងការផលិត ....................១១
២.៣.៣ លក្ខណៈនៃការគ្រប់គ្រងការផលិត ....................១១
២.៣.៤ អត្ថប្រយោជន៍នៃការគ្រប់គ្រងការផលិត ....................១២

## ជំពូកទី៣
## ប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិតរបស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)

៣.១ ស្ថានភាពទូទៅរបស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា) ....................១៣
៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន....................១៣
៣.១.២ បេសកកម្ម ទស្សនវិស័យ និងគោលដៅរបស់ក្រុមហ៊ុន....................១៤
៣.១.៣ រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន....................១៤
៣.២ យុទ្ធសាស្ត្រនៃការគ្រប់គ្រងដំណើរការផលិតឱ្យមានប្រសិទ្ធភាពរបស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា) ....................១៥
៣.២.១ ដំណើរការនៃការផលិត ....................១៥
ក. ការរៀបចំវត្ថុធាតុដើម....................១៥
ខ. ដំណើរការផលិត....................១៦
គ. ដំណើរការវេចខ្ចប់ផលិតផល ....................១៧
ឃ. ការត្រួតពិនិត្យគុណភាពផលិតផល ....................១៨
ង. ការថែទាំ និងការស្តុកទុកផលិតផលសម្រេច ....................១៩
៣.២.២ យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងដំណើរការផលិតឱ្យមានប្រសិទ្ធភាព....................១៩
ក. ការធ្វើផែនការនៃដំណើរការផលិត ....................១៩
ខ. ការគ្រប់គ្រងវត្ថុធាតុដើមឱ្យមានប្រសិទ្ធភាព....................២០
គ. ការគ្រប់គ្រង និងបែងចែកកម្លាំងពលកម្ម ....................២១
ឃ. ការគ្រប់គ្រងពេលវេលាផលិត....................២៣
ង. ការគ្រប់គ្រងចំណាយឱ្យមានប្រសិទ្ធភាព ....................២៤
៣.៣ អត្ថប្រយោជន៍នៃការគ្រប់គ្រងដំណើរការផលិតឱ្យមានប្រសិទ្ធភាព....................២៥

## ជំពូកទី៤: ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង....................២៨
៤.២ ការវិភាគលើចំណុចខ្សោយ....................២៨

**ជំពូកទី៥: សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

៥.១ សេចក្តីសន្និដ្ឋាន ........................................................................................................ ២៩
៥.២ ការផ្តល់អនុសាសន៍ .................................................................................................. ២៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្ដីផ្ដើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលកំពុងអភិវឌ្ឍជឿនលឿនគួរឱ្យកត់សម្គាល់ ក្រោមការដឹកនាំពីរាជរដ្ឋាភិបាល។ យើងបានសង្កេតឃើញថា រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាបានកំពុងពួតដៃគ្នា ពង្រឹងសេដ្ឋកិច្ចជាតិឱ្យមានភាពរឹងមាំ ដើម្បីប្រកួតប្រជែងជាមួយប្រទេសនៅក្នុងតំបន់ ក៏ដូចជាប្រទេសនានា នៅលើពិភពលោក។ សេដ្ឋកិច្ចកម្ពុជា រីកចម្រើនទៅបានត្រូវពឹងផ្អែកទៅលើវិស័យសំខាន់ៗជាច្រើនដូចជា៖ វិស័យកសិកម្ម វិស័យពាណិជ្ជកម្ម វិស័យឧស្សាហកម្ម និងវិស័យទេសចរណ៍ជាដើម។

ក្នុងនោះដែរ វិស័យឧស្សាហកម្ម ក៏បានដើរតួយ៉ាងសំខាន់ផងដែរនៅក្នុងខឿនសេដ្ឋកិច្ចជាតិ ដោយវិស័យនេះ បានផ្ដល់នូវការងារដល់ប្រជាជនជាច្រើន និងកាត់បន្ថយកម្រិតក្រីក្រ បង្កើនផលិតផលសរុបក្នុងស្រុក (GDP)។ មិនតែប៉ុណ្ណោះទេ ផ្នែកផលិតកម្មជួយបង្កើនដល់ការនាំចេញ និងចំណូលពីបរទេស ដែលអាចនាំចេញទៅទីផ្សារអន្តរជាតិ ដែលធ្វើឱ្យមានតុល្យភាពពាណិជ្ជកម្ម ក៏ដូចជាជួយបង្កើនការវិនិយោគក្នុងប្រទេសដោយបានជួយឱ្យមានស្ថិរភាពហិរញ្ញវត្ថុជាដើម។ ជាក់ស្ដែង ផលិតកម្មមួយអាចដំណើរការទៅបានដោយមានប្រសិទ្ធភាព ពោលគឺអាស្រ័យទៅលើការរៀបចំប្រព័ន្ធគ្រប់គ្រងឱ្យបានត្រឹមត្រូវដូចជា៖ ការធ្វើផែនការ ការចាត់តាំងការងារ ការដឹកនាំ ការគ្រប់គ្រងស្តុកវត្ថុធាតុដើម និងការត្រួតពិនិត្យលទ្ធផលជាដើម។

ដោយបានមើលឃើញពីអត្ថប្រយោជន៍ នៃវិស័យឧស្សាហកម្ម ចំពោះសេដ្ឋកិច្ចជាតិបែបនេះហើយ ទើបក្រុមយើងខ្ញុំបានសម្រេចចិត្ត សិក្សាស្រាវជ្រាវបន្ថែមឱ្យបានលម្អិតទៅលើ ប្រធានបទមួយក្រោមចំណងជើងថា “*ប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិតរបស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)*” ដើម្បីបង្កើនចំណេះដឹងបន្ថែម និងទុកជាឯកសារទៅដល់ប្អូនៗជំនាន់ក្រោយៗទៀត។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

យើងបានដឹងរួចហើយថា សេដ្ឋកិច្ចជាតិរបស់ប្រទេសនីមួយៗនៅលើពិភពលោក ត្រូវពឹងផ្អែកទៅលើវិស័យជាច្រើន ដើម្បីអភិវឌ្ឍន៍ខ្លួនទៅមុខបានយ៉ាងឆាប់រហ័ស។ បច្ចុប្បន្នប្រទេសកម្ពុជា ជាប្រទេសមួយកំពុងស្ថិតនៅលើផ្លូវឆ្ពោះទៅរក សមាហរណកម្មសេដ្ឋកិច្ចក្នុងកម្រិតតំបន់ និងពិភពលោក។ នាពេលអនាគតការប្រកួតប្រជែងទៅលើទីផ្សារក្នុងស្រុក និងក្រៅស្រុកនឹងមានការកើនឡើង អាស្រ័យហេតុនេះវិស័យឧស្សាហកម្មក៏ជាចំណែកមួយដែលបានដើរតួយ៉ាងសំខាន់នៅក្នុងចរន្តសេដ្ឋកិច្ចកម្ពុជាផងដែរ ក្នុងការជួយឱ្យដំណើរការសេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើនលូតលាស់។ ក្នុងវិស័យឧស្សាហកម្មកម្ពុជា ត្រូវបានបែងចែកជា២សំខាន់ៗគឺ ឧស្សាហកម្មធុនធ្ងន់ និង ឧស្សាហកម្មធុនស្រាល។ តួយ៉ាងបើយើងសង្កេតមើលទៅលើពិភពលោក មិនថាប្រទេសកម្ពុជា ឬប្រទេសដទៃផ្សេងទៀតទេសុទ្ធសឹងតែមាននូវបណ្ដុំនៃផ្នែកផលិតកម្មដែលជាចំណែកមួយក្នុងការធ្វើឱ្យសេដ្ឋកិច្ចជាតិមានការចម្រើន។ អ្វីដែលរឹតតែពិសេសថែមទៀតនោះគឺគ្រប់ក្រុមហ៊ុនផលិតកម្មត្រូវធ្វើយ៉ាងណា ដើម្បីឱ្យដំណើរការផលិត ផលិតផលរបស់ខ្លួនទទួលបានជោគជ័យខ្ពស់នៅក្នុងដំណើរការផលិត

និងមានការទទួលស្គាល់ស្តង់ដារគុណភាព អនាម័យពីស្ថាប័នជាតិ និងអន្តរជាតិ។ ដូច្នេះហើយ ឆ្លងតាមការបកស្រាយខាងលើ យើងក៏មានសំណួរមួយចំនួនលើកឡើងដើម្បីចោទជាបញ្ហាដូចខាងក្រោម៖

១. តើក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា) ត្រូវមានយុទ្ធសាស្ត្រអ្វីខ្លះ ដើម្បីគ្រប់គ្រងដំណើរការផលិតឱ្យមានប្រសិទ្ធភាព?

២. តើការគ្រប់គ្រងដំណើរការផលិតឱ្យមានប្រសិទ្ធភាពបានផ្តល់ផលប្រយោជន៍អ្វីខ្លះ ដល់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ជាការពិតណាស់ ដើម្បីឱ្យការសិក្សាស្រាវជ្រាវមួយប្រកបដោយភាពជោគជ័យនោះ គឺយើងត្រូវកំណត់នូវគោលបំណងឱ្យបានច្បាស់លាស់ជាមុនសិន។ ជាមួយគ្នានេះដែរ គោលបំណងនៃការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំទៅលើប្រធានបទ ប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិតក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា) គឺផ្តោតទៅលើចំណុចសំខាន់ៗមួយចំនួនដូចជា៖

- ស្វែងយល់អំពីទ្រឹស្តីនៃការគ្រប់គ្រងដំណើរការផលិតក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)។
- សិក្សាយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងដំណើរការផលិតរបស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)។
- សារៈសំខាន់ក្នុងការគ្រប់គ្រងដំណើរការផលិតឱ្យមានប្រសិទ្ធភាព។
- សិក្សាអំពីដំណើរការសង្វាក់ផលិតកម្ម។

## ១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំនិងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺសិក្សាទៅលើប្រធានបទ៖ «ប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិតរបស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)» ដែលសិក្សាវិភាគទៅលើការគ្រប់គ្រងដំណើរការផលិតរបស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា) ដែលយើងនឹងធ្វើការលើកយកមកស្រាវជ្រាវតែទៅលើ វិធីសាស្ត្រ និង យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងធ្វើបែបណាដើម្បីឱ្យដំណើរការផលិតមានប្រសិទ្ធភាពតែប៉ុណ្ណោះ។ ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា) មានអាស័យដ្ឋានស្ថិតនៅ ផ្លូវ P2-100 តំបន់សេដ្ឋកិច្ចពិសេស (RGPPSEZ) សង្កាត់ភ្លើងឆេះរទេះ ខណ្ឌកំបូល រាជធានីភ្នំពេញ។

### ១.៤.២ វិសាលភាព

ក្នុងការសិក្សាស្រាវជ្រាវនេះតម្រូវឱ្យមានវិសាលភាពច្បាស់លាស់ នៃការសិក្សាស្រាវជ្រាវ។ ហើយការស្រាវជ្រាវសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកគណនេយ្យ នេះផងដែរគឺផ្តោតសំខាន់តែទៅលើដំណើរការនៃការគ្រប់គ្រងដំណើរការផលិត របស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា) ដើម្បីឱ្យមានប្រសិទ្ធភាព នៅក្នុងកំឡុងឆ្នាំ២០២៣ យកមកធ្វើការសិក្សាស្រាវជ្រាវប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវត្រូវបានប្រើតាមវិធីសាស្ត្រគុណវិស័យ (Qualitative Methods) ដោយផ្តោតចម្បងទៅលើការវិភាគទិន្នន័យ និងឯកសារដែលបានមកពីក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា) ដែលពាក់ព័ន្ធទៅនឹង

ប្រធានបទ ដើម្បីយកមកវិភាគ និងសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់ អំពីប្រសិទ្ធភាពគ្រប់គ្រងនៃដំណើរការផលិត។

**សម្រាប់សំណួរទី១** ការជ្រើសរើសយកវិធីសាស្ត្រសម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវ គឺតាមបែបគុណវិស័យ ( Qualitative Research ) ដោយផ្តោតសំខាន់ទៅលើទិន្នន័យបន្ទាប់បន្សំ(Secondary Data )។ ចំពោះប្រភពបន្ទាប់បន្សំទាំងនោះរួមមានដូចជា ឯកសាររបស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)ផ្ទាល់ ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗទៀត ថែមទាំងមានជាការសាកសួរព័ត៌មាន ការសម្ភាសន៍ទៅលើអ្នកគ្រប់គ្រង ក្រុមហ៊ុនដោយផ្ទាល់។

**សម្រាប់សំណួរទី២** ការជ្រើសរើសយកវិធីសាស្ត្រសម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវ គឺតាមបែបគុណវិស័យ ( Qualitative Research ) ដោយផ្តោតសំខាន់ទៅលើទិន្នន័យបន្ទាប់បន្សំ (Secondary Data )។ ចំពោះប្រភពបន្ទាប់បន្សំទាំងនោះរួមមានដូចជា ឯកសារផ្សេងៗនៅក្នុងបណ្ណាល័យសាកលវិទ្យាល័យវ៉ាន់ដា ព្រមទាំងឯកសារមួយចំនួនផ្សេងៗទៀតដែលបានមកពីការសាកសួរព័ត៌មាន ពីអ្នកគ្រប់គ្រងផ្នែកផលិតកម្ម និងការសុំជាការផ្តល់មតិយោបល់ការណែនាំពីលោកគ្រូដឹកនាំការស្រាវជ្រាវ ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ក្នុងការសិក្សាស្វែងយល់ការស្រាវជ្រាវនេះ គឺតែងតែមានបង្កប់នូវគោលបំណងយ៉ាងជាក់លាក់មុននិងធ្វើការស្រាវជ្រាវ ដោយគោលបំណងភាគច្រើនផ្តោតលើការចង់យល់ដឹង ចង់ឃើញ និងចង់អនុវត្ត។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយការសិក្សាស្រាវជ្រាវមួយអាចបានជោគជ័យ លុះត្រាតែមាននូវការសិក្សាស្រាវជ្រាវផ្សារភ្ជាប់ជាមួយនិងការអនុវត្ត និងសិក្សាត្រួតពិនិត្យជាក់ស្តែង ដើម្បីឱ្យកាន់តែទទួលបាននូវលទ្ធផល និងប្រសិទ្ធភាពកាន់តែខ្ពស់។

ដោយយោងតាមការសិក្សាកន្លងមកនេះ ក្រុមខ្ញុំទាំងប្រាំនាក់ដែលមានគោលបំណងរួមគ្នាមួយ គឺការសិក្សាបន្ថែមទៅលើ ប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិតរបស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)។ ជាក់ស្តែងនោះ បន្ទាប់ពីបានពិភាក្សាគ្នារួចមក ក្រុមរបស់ខ្ញុំក៏សម្រេចចិត្តជ្រើសរើសយកក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា) នៅក្នុងការគ្រប់គ្រងដំណើរនៃការផលិតនេះ យកមកសិក្សាអំពីចំណុចមួយចំនួនដែលមានសារៈសំខាន់ដូចខាងក្រោម៖

### ក.សារៈសំខាន់សម្រាប់អ្នកស្រាវជ្រាវ

- ស្វែងយល់ដឹងលម្អិតអំពីយុទ្ធសាស្ត្រនៅក្នុងការគ្រប់គ្រងដំណើរការផលិតរបស់ក្រុមហ៊ុន អេប្រាធីហ្វ៊ូដ (ខេមបូឌា)។
- ពង្រីកចំណេះដឹងអំពីការស្រាវជ្រាវ។

### ខ.សារៈសំខាន់សម្រាប់ក្រុមហ៊ុន

- ស្វែងយល់ពីសារៈសំខាន់ក្នុងការគ្រប់គ្រងដំណើរការផលិតឱ្យមានប្រសិទ្ធភាព។
- យល់ច្បាស់អំពីការធ្វើយុទ្ធសាស្ត្រគ្រប់គ្រងការផលិត។
- ស្វែងយល់ពីចំណុចខ្លាំងនិងចំណុចខ្សោយ ដើម្បីរកវិធីសាស្ត្រកែលម្អលើចំណុចខ្សោយ ក៏ដូចជាចំណុចខ្វះខាត និងវិធីសាស្ត្រដោះស្រាយបញ្ហា។

គ.សារៈសំខាន់សម្រាប់សង្គម

- ទុកជាឯកសារយោងសម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយ។
- ការគ្រប់គ្រងដំណើរការផលិតឱ្យមានប្រសិទ្ធភាពអាចជួយបង្កើនសេដ្ឋកិច្ចជាតិ។
- កាត់បន្ថយការប្រើប្រាស់ធនធានធម្មជាតិ ដែលជួយបង្កើនការការពារបរិស្ថាន។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវត្រូវបានធ្វើការរៀបចំតាមលំដាប់ នៃការបែងចែងជាប្រាំជំពូកដូចខាងក្រោម៖

ជំពូកទី១ ៖ **សេចក្តីផ្តើម** : លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហា គោលបំណង ដែនកំណត់ វិសាលភាព វិធីសាស្ត្រ និងសារៈសំខាន់នៃការស្រាវជ្រាវ។

ជំពូកទី២ ៖ **ប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិតរបស់ក្រុមហ៊ុនផលិតកម្ម** : លក្ខណៈទូទៅ និយមន័យ ប្រវត្តិនិងទ្រឹស្តីដែលពាក់ព័ន្ធប្រធានបទ។

ជំពូកទី៣ ៖ **លទ្ធផលនៃការស្រាវជ្រាវ** : ស្ថានភាពទូទៅ យុទ្ធសាស្ត្រនៃការគ្រប់គ្រង និងអត្ថប្រយោជន៍នៃការគ្រប់គ្រង។

ជំពូកទី៤ ៖ **ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ** : ការវិភាគទៅលើចំណុចខ្លាំង និងចំណុចខ្សោយ។

ជំពូកទី៥ ៖ **សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ និងឯកសារយោង។**

# ជំពូកទី២
# ប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិតរបស់ក្រុមហ៊ុនផលិតកម្ម

## ២.១ លក្ខណៈទូទៅនៃប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិត

### ២.១.១ និយមន័យ

ដោយផ្អែកតាមប្រធានបទខាងលើ "**ប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិតរបស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)**" យើងអាចលើកយកមកនូវពាក្យគន្លឹះមួយចំនួនដូចជា៖

- ប្រសិទ្ធភាព (Effectiveness) មានន័យថា សមត្ថភាព ឬលទ្ធផលនៃអ្វីមួយក្នុងការបំពេញភារកិច្ច ឬការងារឱ្យបានសម្រេចល្អ ឬឱ្យបានតាមគោលដៅដែលបានកំណត់។
- ប្រសិទ្ធភាព (Effectiveness) មានន័យថាកម្រិត ឬសមត្ថភាពដែលសម្រេចបានជាលទ្ធផលតាមការគ្រោងទុក ឬ តាមគោលបំណង។
- ប្រសិទ្ធភាព (Effectiveness) គឺជាការសម្រេចបានលទ្ធផលត្រឹមត្រូវ ឬប្រសើរ ដោយប្រើវិធីសាស្ត្រ ឬធនធានដែលមានប្រយោជន៍ជាទីបំផុត[1]។
- ការគ្រប់គ្រង (Management) គឺជាដំណើរការកំណត់គោលដៅ គ្រោងការណ៍ រៀបចំ ដឹកនាំ និងត្រួតពិនិត្យធនធាន ដើម្បីសម្រេចលទ្ធផលដែលបានកំណត់។
- ការគ្រប់គ្រង (Management) គឺជាការប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាព ដើម្បីសម្រេចគោលដៅ[2]។

### ២.១.២ ប្រវត្តិប្រសិទ្ធភាព និងការគ្រប់គ្រង

**ប្រវត្តិនៃការគ្រប់គ្រង** ចាប់ផ្តើមពីសម័យបុរាណដែលអ្នកដឹកនាំបានប្រើគោលការណ៍មូលដ្ឋានក្នុងការរៀបចំ និងគ្រប់គ្រងធនធាន និងកម្លាំងពលកម្មសម្រាប់គម្រោងធំៗ។ នៅក្នុងអំឡុងពេលបដិវត្តន៍ឧស្សាហកម្ម ការយកចិត្តទុកដាក់បានផ្លាស់ប្តូរទៅលើការផលិតជាច្រើន ដែលនាំឱ្យមានការអភិវឌ្ឍនៃការគ្រប់គ្រងវិទ្យាសាស្ត្រដោយលោក Frederick Taylor ដែលបានបញ្ជាក់ពីប្រសិទ្ធភាពតាមរយៈការកែលម្អការងារ។ នៅដើមសតវត្សរ៍ទី ២០ ទ្រឹស្តីបុរាណដូចជាគោលការណ៍គ្រប់គ្រងរបស់ Henri Fayol និងលោក Max Weber បានបង្កើតវិធីសាស្ត្រដែលមានរចនាសម្ព័ន្ធសម្រាប់ការគ្រប់គ្រងអង្គភាពអាជីវកម្ម។ ចលនាទំនាក់ទំនងមនុស្សបានណែនាំពីសារៈសំខាន់នៃសុខុមាលភាព និងជំរុញចិត្តរបស់បុគ្គលិកខណៈពេលដែលការតម្រូវរបស់លោក Maslow បានបង្ហាញពីតួនាទីនៃកត្តាមនុស្សក្នុងផលិតភាព។ នៅពាក់កណ្តាលសតវត្សរ៍ទី២០ ទ្រឹស្តីដូចជា Theory X និង Theory Y របស់លោក Douglas McGregor និងទ្រឹស្តីប្រព័ន្ធ បានសង្កត់ធ្ងន់លើការជំរុញរបស់មនុស្ស និងការពឹងផ្អែកគ្នារបស់អង្គភាព។ នៅចុងសតវត្សរ៍នេះ យុទ្ធសាស្ត្រនៃការគ្រប់គ្រង strategic management TQM និង lean management បានផ្តោតទៅលើការកែលម្អជាបន្តបន្ទាប់ ការត្រួតពិនិត្យគុណភាព និងការបំបាត់ការខ្ជះខាត។ បច្ចុប្បន្ននេះ ការគ្រប់គ្រងត្រូវបានប្រើប្រាស់ ដោយផ្អែកលើបច្ចេកវិទ្យា។

---

[1] វិគីនុក្រម. (២០១៩). *ប្រសិទ្ធភាព.* Retrieved May, 13 2025, from https://km.wiktionary.org/wiki/ប្រសិទ្ធភាព

[2] វិទ្យាស្ថានវ៉ាន់ដា. (២០២៣). *មូលដ្ឋានគ្រឹះនៃការគ្រប់គ្រង.* ទំព័រទី២៥

ដាក់ស្តែងអ្នកគ្រប់គ្រងផ្ទាល់ ចាំបាច់ត្រូវមានភាពបត់បែន ភាពច្នៃប្រឌិត និងការអភិវឌ្ឍន៍ ក្នុងការប្រើប្រាស់បច្ចេកវិទ្យា ឱ្យស្របតាមបរិបទនៅក្នុងសកលលោកដែលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស[3]។

**២.១.៣ ទ្រឹស្តីនៃប្រសិទ្ធភាព និងការគ្រប់គ្រង**

**ក. ទ្រឹស្តីប្រសិទ្ធភាព (Theory of Efficiency)** គឺផ្តោតលើការបង្កើនចំណូលអតិបរមា ខណៈដែលកាត់បន្ថយចំណាយអប្បបរមា។ គំនិតនេះបានចូលរួមក្នុងវិស័យផ្សេងៗ ចាប់តាំងពីសេដ្ឋកិច្ច និងបច្ចេកវិទ្យា រហូតដល់ជីវិតប្រចាំថ្ងៃ។ នៅក្នុងសេដ្ឋកិច្ច ប្រសិទ្ធភាពតែងតែសំដៅទៅលើការបែងចែកធនធានយ៉ាងល្អប្រសើរ ដោយធានាថា ទំនិញ និងសេវាកម្មត្រូវបានផលិត និងចែកចាយដើម្បីបង្កើនសុភមង្គលសាធារណៈឱ្យបានខ្ពស់បំផុត។ នេះអាចពាក់ព័ន្ធនឹងប្រសិទ្ធភាពបច្ចេកទេសដែលផ្តោតលើការផលិតផលិតផលច្រើនបំផុតពីវត្ថុធាតុដើម ដែលបានផ្តល់ ឬប្រសិទ្ធភាពបែងចែកដែលធានាថាធនធានត្រូវបានប្រើដើម្បីផលិតទំនិញ និងសេវាកម្ម ដែលអ្នកប្រើប្រាស់មានតម្លៃបំផុត។ ទោះបីជាមានលក្ខខណ្ឌជាក់លាក់យ៉ាងណាក៏ដោយ គោលការណ៍នៃប្រសិទ្ធភាពនៅតែជាប់ទាក់ទង ដើម្បីសម្រេចបានលទ្ធផលដែលចង់បានជាមួយធនធានដែលត្រូវការតិចបំផុត។ ទស្សនវិជ្ជាប្រសិទ្ធភាពមិនត្រឹមតែផ្តោតលើល្បឿនប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការប្រើប្រាស់ធនធានយ៉ាងល្អបំផុត។ ការវាស់វែងប្រសិទ្ធភាពអាចប្រែប្រួលតាមបរិបទដូចជា ចំនួនផលិតផលក្នុងមួយម៉ោង ឬគម្រោងដែលបញ្ចប់ក្នុងពេលកំណត់។ បច្ចេកវិទ្យា ដើរតួនាទីសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពតាមរយៈការធ្វើតេស្ត និងកម្មវិធីកុំព្យូទ័រ។ លើសពីនេះទៀតប្រសិទ្ធភាពគាំទ្រដល់ការអភិវឌ្ឍដោយកាត់បន្ថយការប្រើប្រាស់ធនធាន និងផលប៉ះពាល់បរិស្ថាន។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិទ្ធភាពមិនមែនជាគោលដៅចុងក្រោយទេ ប៉ុន្តែជាឧបករណ៍ដើម្បីសម្រេចគោលដៅផ្សេងទៀតដូចជាប្រាក់ចំណេញឬសេវាកម្មល្អជាងមុន[4]។

**ខ. ទ្រឹស្តីនៃការគ្រប់គ្រង** មានការចូលរួមពីវិធីសាស្ត្រផ្សេងៗ ដែលបានវិវត្តន៍ទៅតាមពេលវេលា ដើម្បីបង្កើនប្រសិទ្ធភាពនៃការរៀបចំ ការសម្រេចចិត្ត និងការដឹកនាំ ។

- Frederick Taylor៖ “Scientific Management Theory” បានបង្ហាញការគ្រប់គ្រងតាមបែបវិទ្យាសាស្ត្រនៅដើមសតវត្សរ៍ទី២០ ដោយផ្តោតលើប្រសិទ្ធភាព និងផលិតភាពនៅក្នុងកន្លែងធ្វើការ។ លោកជឿជាក់ថា ការងារគួរតែត្រូវបានសិក្សាដោយវិទ្យាសាស្ត្រ ដើម្បីកំណត់វិធីសាស្ត្រល្អបំផុតសម្រាប់ការអនុវត្តការងារ ទ្រឹស្តីរបស់លោកបាននាំឱ្យមានការកែលម្អយ៉ាងសំខាន់ ក្នុងការផលិតកម្មឧស្សាហកម្មប៉ុន្តែត្រូវបានរិះគន់ ចំពោះការផ្តោតទៅលើខ្លាំងចំពោះផលិតផល និងប្រសិទ្ធភាពជាជាងតាមតម្រូវការរបស់អ្នកប្រើប្រាស់។
- Henri Fayol៖ “Administrative Management Theory” បានអភិវឌ្ឍន៍គោលការណ៍គ្រប់គ្រងរដ្ឋបាលដែលផ្តោតលើអង្គភាពទាំងមូល និងតួនាទីរបស់អ្នកគ្រប់គ្រងក្នុងការធានាប្រសិទ្ធភាព។ លោកបានកំណត់មុខងារសំខាន់នៃការគ្រប់គ្រងរួមមាន ការរៀបចំ ការបញ្ជា ការសម្របសម្រួល និងការគ្រប់គ្រង។
- លោក Fayol៖ បានផ្តោតលើការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រង និងរបៀបដែលពួកគេអាចបង្កើតអង្គភាពមួយដែលដំណើរការបានល្អ។

---

[3] FUSU Digital Press. Pindur, Rogers, and Kim. (2020). *ប្រវត្តិប្រសិទ្ធភាព និងការគ្រប់គ្រង*. Retrieved May, 13 2025, from https://fhsu.pressbooks.pub/management/chapter/the-history-of-management/

[4] Intelligent Economist. Prateek Agarwal. (2025, April 7) *ទ្រឹស្តីនៃប្រសិទ្ធភាព*. Retrieved May, 13 2025, from https://www.intelligenteconomist.com/theory-of-efficiency/

- Max Weber៖ "Bureaucratic Management Theory" បានបង្ហាញទស្សនៈគ្រប់គ្រង ដែលបានលើកឡើងអំពីរចនាសម្ព័ន្ធច្បាប់ និងឋានានុក្រមនៅក្នុងអង្គភាព។ លោកបានអះអាងថាអង្គភាពគួរតែដំណើរការដោយផ្អែកលើច្បាប់ និងបទបញ្ញាច្បាស់លាស់ និងការបែងចែកការងារដើម្បីធានាប្រសិទ្ធភាព និងភាពស្មោះត្រង់។

- Elton Mayo៖ "Human Relations Theory" បានអភិវឌ្ឍន៍ទស្សនវិជ្ជាទំនាក់ទំនងមនុស្សតាមរយៈការសិក្សា "Hawthorne" ដ៏ល្បីល្បាញរបស់លោក ដែលបានបង្ហាញថា ការជំរុញទឹកចិត្តរបស់បុគ្គលិក និងទំនាក់ទំនងសង្គមមានឥទ្ធិពលយ៉ាងសំខាន់ទៅលើផលិតភាព។ ខុសពីទស្សនៈមុនដែលផ្តោតលើប្រសិទ្ធភាព និងរចនាសម្ព័ន្ធ បានសង្កត់ធ្ងន់ពីសារៈសំខាន់នៃការពេញចិត្តរបស់កម្មករ ការធ្វើការជាក្រុម និងទំនាក់ទំនងការងារវិជ្ជមាន។ ការស្រាវជ្រាវរបស់លោកបានរកឃើញថា បុគ្គលិកធ្វើការបានល្អជាងមុន នៅពេលដែលពួកគេមានអារម្មណ៍ថាមានតម្លៃ និងមានការចូលរួមក្នុងការសម្រេចចិត្ត[5]។

**២.១.៤ ប្រភេទនៃការគ្រប់គ្រង**

នៅក្នុងប្រព័ន្ធគ្រប់គ្រងមានប្រភេទនៃការគ្រប់គ្រងជាច្រើនផ្សេងៗពីគ្នា ដែលត្រូវបានបង្កើតឡើងដើម្បីបង្កើនប្រសិទ្ធភាព និងគុណភាពរបស់អង្គភាពនីមួយៗតាមប្រភេទផ្សេងពីគ្នា។

**ក. Scientific Management** ដែលបង្កើតឡើងដោយលោក Frederick Winslow Taylor ផ្តោតលើការកែលម្អផលិតភាពតាមរយៈការវិភាគវិទ្យាសាស្ត្រនៃដំណើរការការងារ។ គោលដៅគឺដើម្បីបង្កើនផលិតភាព និងកាត់បន្ថយការខ្ជះខ្ជាយពេលវេលា ឬកម្លាំង។ ប៉ុន្តែវិធីសាស្ត្រនេះត្រូវបាន រិះគន់ ពីព្រោះវាពឹងផ្អែកតែពីលើប្រសិទ្ធភាព និងលទ្ធផល ដោយមើលមនុស្សដូចជាផ្នែកនៃម៉ាស៊ីន ជាជាងការទទួលស្គាល់ថាពួកគេជាមនុស្សដែលមានតម្រូវការ អារម្មណ៍ និងការលើកទឹកចិត្ត។

**ខ. Bureaucratic Management** ដែលបង្កើតឡើងដោយលោក Max Weber សង្កត់ធ្ងន់លើប្រព័ន្ធអង្គភាពដែលមានរចនាបទខ្ពស់ និងផ្អែកលើច្បាប់។ វាជំរុញឱ្យមានភាពច្បាស់លាស់ នីតិវិធីផ្លូវការ និងការលើកកម្ពស់ដោយផ្អែកលើគុណសម្បត្តិដើម្បីរក្សាប្រសិទ្ធភាព ស្មើភាព និងភាពត្រឹមត្រូវ។ ខណៈពេលដែលវិធីសាស្ត្រនេះកាត់បន្ថយការរើសអើង និងបង្កើនស្ថិរភាពរបស់អង្គភាព វាត្រូវបានរិះគន់ចំពោះភាពតឹងរឹងហួសហេតុ ការសម្រេចចិត្តយឺតយ៉ាវ និងការខ្វះភាពបត់បែនក្នុងការឆ្លើយតបទៅនឹងការផ្លាស់ប្តូរ។

**គ. Human Relations Management** ដែលត្រូវបានអភិវឌ្ឍន៍ដោយលោក Elton Mayo តាមរយៈការសិក្សា Hawthorne បានបង្ហាញពីសារៈសំខាន់នៃសុខុមាលភាពបុគ្គលិក ការជំរុញទឹកចិត្ត និងទំនាក់ទំនងសង្គមនៅកន្លែងធ្វើការ។ វាបានបង្ហាញថា បុគ្គលិកដែលពេញចិត្តមានសក្តានុពលជាងមុន ដូចជា ការងារជាក្រុម ការទំនាក់ទំនង និងបរិយាកាសការងារគាំទ្រ ដើរតួនាទីដ៏សំខាន់ក្នុងការបង្កើនសមត្ថភាព។

**ឃ. Leadership Management** ជាប្រភេទដែលគ្រប់គ្រងលើសមត្ថភាពក្នុងការជំរុញ ការណែនាំ និងឥទ្ធិពលលើអ្នកដទៃ។ អ្នកដឹកនាំប្រើវិធីសាស្ត្រនេះ ដោយផ្តោតលើការអភិវឌ្ឍទស្សនវិស័យ ការជំរុញឱ្យបុគ្គលិក និងការបង្កើតវប្បធម៌វិជ្ជមាន។ វាបញ្ជាក់ពីគុណសម្បត្តិដូចជាការទំនាក់ទំនងល្អ ការយល់ចិត្ត និងការកសាងទំនុកចិត្តដើម្បីជំរុញការធ្វើការងារជាក្រុម និងសម្រេចគោលដៅរបស់អង្គភាព។

[5] CFI. CIF Team. (2025). *ទ្រឹស្តីនៃការគ្រប់គ្រង.* Retrieved May, 13 2025, from https://corporatefinanceinstitute.com/resources/management/management-theories/

ង. **Project Management** គឺផ្តោតទៅលើការរៀបចំ ផែនការ និងអនុវត្តគម្រោងជាក់លាក់ដែលមានគោលដៅច្បាស់លាស់ កាលបរិច្ឆេទ និងធនធាន។ វិធីសាស្ត្រនេះតម្រូវឱ្យមានការគ្រប់គ្រងក្រុមការងារ ថវិកា កំណត់ពេលវេលា និងហានិភ័យ ដើម្បីផ្តល់លទ្ធផលដល់គម្រោងឱ្យបានជោគជ័យ។ វាត្រូវបានប្រើជាទូទៅនៅក្នុងឧស្សាហកម្មដូចជាឧស្សាហកម្មបច្ចេកវិទ្យា[6]។

## ២.២ យុទ្ធសាស្ត្រក្នុងការគ្រប់គ្រង

### ២.២.១ និយមន័យយុទ្ធសាស្ត្រនៃការគ្រប់គ្រង

- យុទ្ធសាស្ត្រ (Strategy) មានន័យថាគឺជា សិល្បៈនៃការរៀបចំ ឬការដឹកនាំ ដើម្បីសម្រេចកិច្ចការឱ្យស្របតាមគោលបំណង និងគោលដៅដែលបានកំណត់។
- យុទ្ធសាស្ត្រ (Strategy) គឺសំដៅលើ ការរៀបចំផែនការក្នុងការធ្វើអ្វីមួយ[7]។

### ២.២.២ ប្រវត្តិនៃយុទ្ធសាស្ត្រ

**ប្រវត្តិសាស្ត្រនៃយុទ្ធសាស្ត្រ** យុទ្ធសាស្ត្រមានប្រវត្តិយូរណាស់មកហើយ ដែលចាប់ផ្តើមពីសម័យបុរាណ ក្នុងវិស័យយោធា។ ពាក្យ **"យុទ្ធសាស្ត្រ"** មានដើមមកពីពាក្យជនក្រិកថា ***"Strategos"*** ដែលមានន័យថា "មេបញ្ជាការកងទ័ព"។ នៅក្នុងសម័យនោះយុទ្ធសាស្ត្រមានន័យថា ការធ្វើផែនការប្រយុទ្ធ ការរៀបចំកងទ័ព និងរកវិធីយកឈ្នះសត្រូវ។

មនុស្សល្បីម្នាក់ដែលបានចូលរួមបង្កើតក្បួនយុទ្ធសាស្ត្រតាំងពីដើមគឺ ស៊ុនអ៊ូ *(Sun Tzu)* ដែលជាអ្នកប្រាជ្ញផ្នែកយោធារបស់ប្រទេសចិន។ លោកបាននិពន្ធសៀវភៅឈ្មោះ សិល្បៈនៃសង្គ្រាម *(The Art of War)* ប្រហែល ២ពាន់ឆ្នាំមុន។ នៅក្នុងសៀវភៅនេះ លោកបង្ហាញថា ការធ្វើផែនការ ព្រមទាំងការស្គាល់សត្រូវ ការប្រើកល និងការជៀសវាងការប្រយុទ្ធផ្ទាល់ គឺជាគន្លឹះសំខាន់ៗនៃជ័យជម្នះ។ សៀវភៅនេះមិនត្រឹមតែអាននៅក្នុងវិស័យយោធាប៉ុណ្ណោះទេ ប៉ុន្តែត្រូវបានអានក្នុងមុខជំនាញអាជីវកម្ម និងភាពជាអ្នកដឹកនាំផងដែរ។

នៅភាគខាងលិច ដូចជាលោក Alexander the Great និង Julius Caesar ក៏បានប្រើយុទ្ធសាស្ត្រដើម្បីឈ្នះសង្គ្រាម និងគ្រប់គ្រងអំណាចផងដែរ។ ពួកគេមិនត្រឹមតែមានយុទ្ធសាស្ត្រក្នុងការប្រយុទ្ធទេ ប៉ុន្តែថែមទាំងមានការគ្រប់គ្រងធនធាន និងជំនាញក្នុងការគ្រប់គ្រងមនុស្ស។ ចាប់តាំងពីសម័យអាណាចក្រទាំងនោះ រហូតដល់សម័យអាណាចក្រអ៊ឺរ៉ុប វិទ្យាសាស្ត្រនៃយុទ្ធសាស្ត្របានរីកចម្រើន ដោយចាប់ផ្តើមចូលទៅក្នុងវិស័យការទូត ការគ្រប់គ្រង និងការសម្រេចបាននូវគោលដៅ។

ចូលទៅសតវត្សរ៍ទី១៩ និង ២០ នៅពេលឧស្សាហកម្មចាប់ផ្តើមរីកចម្រើន ក្រុមហ៊ុនជាច្រើនបានដឹងថា ត្រូវការគំនិតយុទ្ធសាស្ត្រដើម្បីប្រកួតប្រជែង។ ពួកគេបានប្រើផែនការយុទ្ធសាស្ត្រ ដើម្បីសម្រេចថាតើត្រូវផលិតអ្វី ត្រូវចូលទីផ្សារណា និងត្រូវប្រកួតប្រជែងយ៉ាងដូចម្តេច។ ក្រោយសង្គ្រាមលោកលើកទីពីរ គំនិតយុទ្ធសាស្ត្រដែលប្រើក្នុងយោធា ត្រូវបានយកមកបំលែងប្រើនៅក្នុងសេដ្ឋកិច្ច និងអាជីវកម្ម។ មានក្រុមហ៊ុនជាច្រើនបានជួលអ្នកប្រឹក្សាយោបល់ ដើម្បីជួយរៀបចំផែនការយុទ្ធសាស្ត្រប្រចាំឆ្នាំរបស់ខ្លួន។

បច្ចុប្បន្ននេះ យុទ្ធសាស្ត្រមិនត្រឹមតែប្រើក្នុងសង្គ្រាម ឬអាជីវកម្មទេ ប៉ុន្តែត្រូវបានប្រើគ្រប់វិស័យ ដូចជាការអប់រំ ការរដ្ឋបាល ការលេងកីឡា និងការរីកចម្រើនផ្ទាល់ខ្លួន។ វាមិនមែនតែសម្រាប់ជ័យជំនះ ឬការរក

---

[6] Asana. Julia Martins. (2025, May 19). *ប្រភេទនៃការគ្រប់គ្រង*. Retrieved June, 15 2025, from https://asana.com/resources/management-styles

[7] វិគីនុក្រម. (2016, June 5). *យុទ្ធសាស្ត្រ*. Retrieved July, 15 2025, from https://km.wiktionary.org/យុទ្ធសាស្ត្រ

ប្រាក់ចំណេញនោះទេ ប៉ុន្តែសម្រាប់ការគិតឱ្យបានច្បាស់ អភិវឌ្ឍគោលដៅ និងប្រើប្រាស់ធនធានឱ្យបានល្អបំផុត។ ចាប់ពីជំនាន់បុរាណរហូតដល់សម័យឥឡូវនេះ យុទ្ធសាស្ត្របានក្លាយជាឧបករណ៍សំខាន់មួយនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃផងដែរ[8]។

**២.២.៣ ទ្រឹស្តីនៃយុទ្ធសាស្ត្រ**

**ទ្រឹស្តីនៃយុទ្ធសាស្ត្រ (Theory of Strategy)** គឺជាការពន្យល់អំពីរបៀបដែលអ្នកគ្រប់គ្រង ឬអង្គភាពសម្រាប់ធ្វើផែនការ និងចាត់វិធានការ ដើម្បីសម្រេចបានគោលបំណងយ៉ាងមានប្រសិទ្ធភាព។ វាពាក់ព័ន្ធនឹងការជ្រើសរើសយ៉ាងច្បាស់ថាត្រូវប្រើប្រាស់ធនធានមានកំណត់យ៉ាងដូចម្តេច ខណៈពេលដែលត្រូវបត់បែនទៅតាមការផ្លាស់ប្តូរនៅបរិបទជុំវិញ។ ដំណើរការនេះភាគច្រើនចាប់ផ្តើមពីការកំណត់គោលដៅយ៉ាងច្បាស់ ពីព្រោះបើគ្មានគោលដៅច្បាស់ វាគឺលំបាកក្នុងការបង្កើតផែនការដែលមានគុណភាព។ បន្ទាប់ពីកំណត់គោលដៅរបស់អ្នក គឺត្រូវវិភាគស្ថានភាព។ នេះមានន័យថាត្រូវពិនិត្យបរិបទក្រៅដូចជា ស្ថានការណ៍ទីផ្សារ និងការប្រកួតប្រជែងជាមួយនឹងកត្តាផ្ទៃក្នុងដូចជាចំណុចខ្លាំង និងចំណុចខ្សោយ។ ការវិភាគនេះជួយស្វែងរកឱកាស និងបញ្ហាដែលត្រូវតែដោះស្រាយ។ ជាមួយនឹងព័ត៌មាននេះ គេអាចបង្កើតយុទ្ធសាស្ត្រ ឬផែនការដែលបញ្ជាក់ពីសកម្មភាពដែលត្រូវធ្វើ និងរបៀបចែកចាយធនធាន ដើម្បីសម្រេចគោលបំណង។ បន្ទាប់ពីផែនការ បានរៀបចំរួច វាត្រូវបានអនុវត្តតាមសកម្មភាពដែលបានកំណត់។ ទោះជាយ៉ាងណា យុទ្ធសាស្ត្រមិនមែនជារឿងថេរទេ។ វាត្រូវការតាមដាន និងវាយតម្លៃជាបន្តបន្ទាប់ ដើម្បីពិនិត្យមើលថាតើផែនការនេះដំណើរការល្អឬទេ។ ប្រសិនបើដំណើរការមិនល្អ ត្រូវប្តូរផែនការ ដើម្បីឆ្លើយតបទៅនឹងបញ្ហាថ្មី ឬការផ្លាស់ប្តូរនៅបរិបទ។

ជាយូរមកហើយ អ្នកប្រាជ្ញជាច្រើន បានមានឥទ្ធិពលដល់ការយល់ដឹងរបស់យើងអំពីយុទ្ធសាស្ត្រ។ លោក Michael Porter បានណែនាំពីគំនិតអំពីអាទិភាពប្រកួតប្រជែង ដែលពន្យល់ថា សាជីវកម្មអាចទទួលបានជោគជ័យដោយការបន្ថយថ្លៃកាន់តែទាប ឬបង្កើតភាពខុសប្លែកលើផលិតផលរបស់ខ្លួន។ ខណៈដែលលោក Henry Mintzberg បានវិភាគថា គំនិតផែនការរឹងមាំមិនត្រូវបានទទួលយកទាំងស្រុងទេ ហើយយុទ្ធសាស្ត្រជាច្រើនត្រូវបានបង្កើតឡើងដោយសកម្មភាព និងការសម្រេចចិត្តប្រចាំថ្ងៃ មិនមែនពីផែនការផ្លូវការតែប៉ុណ្ណោះ។ ទស្សនៈមួយទៀតមកពីទ្រឹស្តីហ្គេម (Game Theory) ដែលថា យុទ្ធសាស្ត្រជាសំណុំជម្រើសដែលធ្វើឡើង ដើម្បីឆ្លើយតបនឹងសកម្មភាពរបស់អ្នកផ្សេង ក្នុងករណីមានការប្រកួតប្រជែង និងអត្រានៃភាពមិនប្រាកដ។ នេះបង្ហាញថា យុទ្ធសាស្ត្រមិនមែនតែផែនការតែប៉ុណ្ណោះទេ ប៉ុន្តែគឺជាការរំពឹងទុក និងឆ្លើយតបដល់អ្នកផ្សេងផងដែរ។

សង្ខេបមកវិញ ទ្រឹស្តីអំពីយុទ្ធសាស្ត្រជួយយើងយល់ពីរបៀបធ្វើជម្រើសឆ្លាតវៃ ដើម្បីទទួលបានជោគជ័យទោះបីមានភាពមិនប្រាកដ និងការប្រកួតប្រជែងក៏ដោយ។ វាមិនត្រឹមតែប្រើសម្រាប់អាជីវកម្មទេ តែក៏អាចប្រើសម្រាប់យោធា នយោបាយ និងគោលបំណងផ្ទាល់ខ្លួនផងដែរ។ មានយុទ្ធសាស្ត្រល្អមានន័យថា អ្នកដឹងថាតើអ្វីដែលអ្នកចង់បាន យល់ពីស្ថានភាពរបស់អ្នក រៀបចំផែនការប្រតិបត្តិ និងត្រៀមខ្លួនប្តូរតាមការផ្លាស់ប្តូរ។ វាជាវិធីមួយដែលធ្វើឱ្យឱកាសសម្រេចបានជោគជ័យក្នុងស្ថានភាពស្មុគស្មាញកាន់តែច្រើន[9]។

---

[8] Strategyskills. Rich Horwath. (2020, July 1) *ទ្រឹស្តីពាក់ព័ន្ធនឹងយុទ្ធសាស្ត្រ*. Retrieved May, 15 2025, from https://www.strategyskills.com/the-origin-of-strategy/

[9] MILITARY STRATEGY MAGAZINE. M.L.R. Smith. (2022). *ទ្រឹស្តីនៃយុទ្ធសាស្ត្រ* . Retrieved July, 15 2025, from https://www.militarystrategymagazine.com/article/on-efficacy-a-beginners-guide-to-strategic-theory/

### ២.២.៤ ប្រភេទនៃយុទ្ធសាស្ត្រនៃការគ្រប់គ្រង

នៅក្នុងការគ្រប់គ្រងគេតែងតែប្រើយុទ្ធសាស្ត្រជាច្រើន ដើម្បីសម្រេចបាននូវគុណភាព និងប្រសិទ្ធភាព នៅក្នុងការគ្រប់គ្រងអាជីវកម្មណាមួយឱ្យដើរទៅមុខរលូន និងមានការអភិវឌ្ឍទៅមុខជានិច្ច។ ខាងក្រោមនេះគឺជាប្រភេទយុទ្ធសាស្ត្រនៃការគ្រប់គ្រងធំៗទាំង ៤ មានដូចជា៖

ក. Corporate Strategy៖ គឺជាយុទ្ធសាស្ត្រដែលមានកម្រិតខ្ពស់បំផុត ហើយសំខាន់បំផុតសម្រាប់ក្រុមហ៊ុន។ វាជួយកំណត់ទិសដៅសរុបនៃអាជីវកម្ម និងកំណត់អំពីដំណើរការអាជីវកម្មរយៈពេលវែង។ ក្រុមហ៊ុនតែងតែប្រើយុទ្ធសាស្ត្រនេះ ដើម្បីសម្រេចថាគួរចូលទៅក្នុងទីផ្សារថ្មី ឬដកខ្លួនចេញពីទីផ្សារដែលមិនមានផល។ លើសពីនេះ វាក៏ពាក់ព័ន្ធនឹងការសម្រេចចិត្តធំៗដូចជា ការរួមបញ្ចូលក្រុមហ៊ុន ការទិញយកក្រុមហ៊ុនផ្សេងៗ ការបោះបង់អាជីវកម្មមួយចំនួន ឬការចាប់ផ្តើមអាជីវកម្មថ្មីៗ។ គោលបំណងសំខាន់របស់យុទ្ធសាស្ត្រ Corporate Strategy គឺការបង្កើនតម្លៃសរុបរបស់ក្រុមហ៊ុន និងធានាថា ក្រុមហ៊ុនអាចរស់នៅបានយូរនៅក្នុងទីផ្សារ។

ខ. Business Strategy៖ យុទ្ធសាស្ត្រនេះផ្តោតទៅលើវិធីសាស្ត្រដើម្បីប្រកួតប្រជែងក្នុងទីផ្សារ។ វាជួយក្រុមហ៊ុនសម្រេចចិត្តថា តើគួរធ្វើដូចម្តេចដើម្បីទាក់ទាញអតិថិជន និងធ្វើឱ្យខ្លួនខុសពីគូប្រកួតប្រជែង។ ឧទាហរណ៍ អាជីវកម្មមួយអាចជ្រើសរើសផ្តោតលើការបញ្ចុះតម្លៃ ដើម្បីទាក់ទាញអតិថិជនដែលចង់បានតម្លៃថោក។ ខ្លះទៀតអាចផ្តោតលើគុណភាព ឬផ្តល់បទពិសោធន៍សេវាកម្មល្អ ដើម្បីក្លាយជាជម្រើសដ៏ពេញនិយម។ ម្យ៉ាងវិញទៀត អាជីវកម្មមួយចំនួនអាចបម្រើតែទីផ្សារតូចៗ ឬក្រុមអតិថិជនពិសេស ដើម្បីទទួលបានអតិថិជនឱ្យច្រើន និងធានាបាននូវផលចំណេញប្រសើរជាងគេ។ តាមរយៈយុទ្ធសាស្ត្រនេះ ក្រុមហ៊ុនអាចបង្កើនតម្លៃសម្រាប់អតិថិជន ហើយសម្រេចបានភាពជោគជ័យក្នុងការប្រកួតប្រជែង។

គ. Functional Strategy៖ ជាការរៀបចំផែនការសម្រាប់ផ្នែកនីមួយៗរបស់ក្រុមហ៊ុន ដូចជាផ្នែកទីផ្សារ ផ្នែកហិរញ្ញវត្ថុ ផ្នែកផលិតកម្ម និងផ្នែកធនធានមនុស្ស។ ផ្នែកនីមួយៗនឹងចាត់វិធានការផ្សេងៗដើម្បីសម្រេចគោលបំណងរបស់ខ្លួន។ ឧទាហរណ៍ ផ្នែកទីផ្សារអាចផ្តោតទៅលើការផ្សព្វផ្សាយតាមបណ្តាញសង្គម ដើម្បីបង្កើនការទាក់ទាញអតិថិជនថ្មី ខណៈផ្នែកហិរញ្ញវត្ថុអាចផ្តោតលើការគ្រប់គ្រងថវិកា ធ្វើបច្ចុប្បន្នភាពបញ្ជី និងកាត់បន្ថយចំណាយអោយបានល្អបំផុត។ ផ្នែកផលិតកម្មអាចផ្តោតលើការកែលម្អគុណភាពផលិតផល និងបន្ថយកាកសំណល់ ដើម្បីបង្កើនប្រសិទ្ធភាព។ ផ្នែកធនធានមនុស្សអាចផ្តោតលើការជ្រើសរើសបុគ្គលិកថ្មី ការបណ្តុះបណ្តាល និងការរក្សាបុគ្គលិកឱ្យបានយូរ។ គ្រប់ផ្នែកទាំងអស់ត្រូវធ្វើការសហការគ្នា ដើម្បីធានាបានការសម្រេចគោលបំណងរួមរបស់ក្រុមហ៊ុន។

ឃ. Operational Strategy៖ គឺជាយុទ្ធសាស្ត្រដែលផ្តោតលើការអនុវត្តការងារប្រចាំថ្ងៃ និងធានាបាននូវប្រសិទ្ធភាពក្នុងអាជីវកម្ម។ វាពាក់ព័ន្ធនឹងការកំណត់របៀបធ្វើការងារ ការរៀបចំដំណើរការផលិត ការគ្រប់គ្រងស្តុក និងការផ្គត់ផ្គង់ដល់អតិថិជន។ ឧទាហរណ៍ ក្រុមហ៊ុនផលិតមួយអាចយកយុទ្ធសាស្ត្រនេះមកកែលម្អលើដំណើរការផលិត ដើម្បីបន្ថយពេលវេលា និងចំណាយក្នុងការផលិត។ វាក៏អាចធ្វើការអភិវឌ្ឍលើបច្ចេកវិទ្យាថ្មីៗ ដើម្បីធ្វើអោយដំណើរការងារច្រើនមានប្រសិទ្ធភាពនិងគុណភាពល្អប្រសើរជាងមុន។ យុទ្ធសាស្ត្រ

ប្រតិបត្តិការ ជាធម្មតាជួយអោយអាជីវកម្មអាចអនុវត្តយុទ្ធសាស្ត្រសេវាកម្ម និងអាជីវកម្មបានជោគជ័យ ព្រោះវាធានាថា ការងាររៀងរាល់ថ្ងៃអាចដំណើរការបានយ៉ាងរលូន[10]។

## ២.៣ អត្ថប្រយោជន៍នៃការគ្រប់គ្រងការផលិត

### ២.៣.១ និយមន័យ

- ការផលិត (Production) គឺជាការបង្កើតផល ការធ្វើឱ្យបានផល ការបង្ហាញឬបញ្ចេញផលឱ្យឃើញជាក់ស្តែង អំពើដែលនាំឱ្យបានសម្រេចផល។
- ការផលិត (Production) គឺជាដំណើរការបង្កើត ឬបម្លែងធនធានដើម ទៅជាផលិតផល ឬសេវាកម្ម ដែលអាចបំពេញតម្រូវការរបស់អតិថិជន និងទីផ្សារ[11]។

### ២.៣.២ ប្រវត្តិនៃការគ្រប់គ្រងការផលិត

**ប្រវត្តិនៃផលិតកម្ម** បង្ហាញពីការវិវឌ្ឍន៍នៃវិធីសាស្ត្រដែលមនុស្សបានប្រើប្រាស់ក្នុងការបង្កើតទំនិញ និងសេវាកម្មក្នុងរយៈពេលវែង។ នៅសម័យបុរាណ មនុស្សបានពឹងផ្អែកលើឧបករណ៍ធម្មតា ដើម្បីប្រមូលអាហារ និងក្រោយមកធ្វើកសិកម្មសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ។ នៅពេលកសិកម្មមានការរីកចម្រើន សហគមន៍បានបង្កើតអាហារលើសតម្រូវ ដែលជម្រុញឱ្យមានការជួញដូរ និងការចែកចាយ។ នៅសម័យអាណាចក្រចាស់ ការផលិតត្រូវបានធ្វើដោយដៃ និងរៀបចំតាមរយៈសហគមន៍ ដែលមិនបានពង្រឹងផ្នែកគ្រប់គ្រងគុណភាពនៃទំនិញ។ ការផ្លាស់ប្តូរដ៏សំខាន់បំផុតកើតឡើងនៅសតវត្សរ៍ទី18 និង19ជាមួយនឹងបដិវត្តន៍ឧស្សាហកម្ម ដែលម៉ាស៊ីនបានជំនួសឧបករណ៍ដៃ ហើយរោងចក្រក៏បានកើតឡើង ដែលជម្រុញ ការផលិត និងផ្លាស់ប្តូរពីការងារនៅផ្ទះ ទៅធ្វើការនៅរោងចក្រ។ ចូលមកសតវត្សរ៍ទី21 ការផលិតបានបន្តអភិវឌ្ឍន៍តាមរយៈបច្ចេកវិទ្យា ឌីជីថល បញ្ញាសិប្បនិម្មិត ឧបករណ៍រ៉ូបូត និងប្រព័ន្ធឆ្លាតវៃ ដែលធ្វើឱ្យការផលិតកាន់តែរហ័ស ច្បាស់លាស់ និងមានភាពចីរភាព។ សព្វថ្ងៃនេះ ការផលិតក៏ផ្តោតលើភាពបត់បែន ការផលិតតាមតម្រូវការអតិថិជន និងការយកចិត្តទុកដាក់ដល់បរិស្ថាន ដើម្បីបង្កើតសេដ្ឋកិច្ចសកលសម័យថ្មីដែលមានប្រសិទ្ធភាព[12]។

### ២.៣.៣ លក្ខណៈនៃការគ្រប់គ្រងការផលិត

លក្ខណៈនៃដំណើរការផលិតគឺជាប្រព័ន្ធស្មុគស្មាញដែលមានលក្ខណៈសំខាន់ជាច្រើនដែលជួយធ្វើឱ្យវាធ្វើការយ៉ាងមានប្រសិទ្ធភាព និងមានសមត្ថភាព។ វាត្រូវការធាតុចូលបន្ថែម (inputs) ដែលមានវត្ថុធាតុដើម កម្លាំងពលកម្មការងារ គ្រឿងចក្រនិងថាមពល ដែលត្រូវបានបំលែងជាផលិតផលរួមតាមដំហាននានា។ ដំណើរការផ្លាស់ប្តូរនេះត្រូវបានអនុវត្តឱ្យដំណើរការដូចជាការចងក្រង ការផលិត ឬការវេចខ្ចប់ ដែលបំលែងការបញ្ចូលទៅជាការបញ្ចេញ។ បច្ចេកវិទ្យាមានតួនាទីសំខាន់ក្នុងការកែលម្អល្បឿន ចំណាយ និងគុណភាពនៃការផលិត ខណៈដែលកម្លាំងការងារមានសារៈសំខាន់ក្នុងការអនុវត្តសកម្មភាពនានាដែលត្រូវការ។ ការត្រួតពិនិត្យគុណភាពគឺជាលក្ខណៈសំខាន់មួយ ដើម្បីធ្វើឱ្យប្រាកដថាផលិតផលនីមួយៗស្របតាមស្តង់ដារដែលត្រូវការ និងការពារកំហុស។ ការគ្រប់គ្រងស្តុកមានតួនាទីសំខាន់ក្នុងការរក្សាផលិតផលដែលបានបញ្ចប់ ហើយ

[10] GeeksforGeeks. (225, July 23). *ប្រភេទយុទ្ធសាស្ត្រនៃការគ្រប់គ្រង*. Retrieved August, 15 2025, from https://www.geeksforgeeks.org/business-studies/types-of-strategies/

[11] ANT. (2018). *និយមន័យការផលិត*. Retrieved August, 15 2025, from http://dict.antkh.com/dictionaries/production.aspx

[12] Interdisciplinary Professional Programs. (2024, November 14). *ប្រវត្តិនៃការផលិត*. Retrieved August, 16 2025, from https://interpro.wisc.edu/the-history-and-evolution-of-manufacturing

ជៀសវាងការរាំងខ្ទប់ក្នុងការផលិត។ ប្រសិទ្ធភាពគឺជាសកម្មភាពវាស់ថាអាទិភាពនៃការបំលែងធនធានទៅជាផលិតផល ដែលប្រសិទ្ធភាពខ្ពស់នឹងកាត់បន្ថយសំណល់ និងថ្លៃដើម។ ការផ្លាស់ប្តូរតាមតម្រូវការ និងវិធីសាស្ត្រផលិតផងដែរ ជាលក្ខណៈមួយដែលអាចធ្វើការប្រើប្រាស់ការផលិតឱ្យមានភាពអាចបត់បែនតាមការប្រែប្រួលនៃតម្រូវការឬវិធីសាស្ត្រ។ ពេលវេលាផលិត (lead time) មានសារៈសំខាន់ក្នុងការបញ្ជាក់ពីរយៈពេលដែលត្រូវការដើម្បីបញ្ចប់ការផលិតផលិតផល។ ការប្រើប្រាស់ស្វ័យប្រវត្តិ (Automation) អាចកាត់បន្ថយការចូលរួមរបស់មនុស្ស និងបន្ថែមល្បឿន និងភាពត្រឹមត្រូវក្នុងការផលិត។ ចុងក្រោយ ការរួមបញ្ចូលខ្សែបញ្ជូនផលិតផល (supply chain integration) ធ្វើឱ្យមានការសហការណ៍ក្នុងការផ្គត់ផ្គង់ឧបករណ៍ សម្ភារៈ និងផលិតផលដែលបានបញ្ចប់ពីអ្នកផ្គត់ផ្គង់ទៅអ្នកចែកចាយ ហើយធ្វើឱ្យមានប្រសិទ្ធភាពក្នុងដំណើរការផលិតទាំងមូល[13]។

**២.៣.៤ អត្ថប្រយោជន៍នៃការគ្រប់គ្រងការផលិត**

ការផលិតមានអត្ថប្រយោជន៍ជាច្រើនសម្រាប់សេដ្ឋកិច្ច និងសង្គមទាំងមូល។ អត្ថប្រយោជន៍សំខាន់មួយគឺការបង្កើតការងារ ដោយវិស័យផលិតផ្តល់ឱកាសការងារជាច្រើនសម្រាប់មនុស្សជាច្រើនជាមួយជំនាញផ្សេងៗពីកម្មករដល់វិស្វករ។ ការផលិតក៏ជួយជម្រុញកំណើនសេដ្ឋកិច្ចដោយការផលិត និងនាំចេញផលិតផលធ្វើឱ្យមានការចូលរួមយ៉ាងសំខាន់ក្នុងផលិតផលក្នុងស្រុក (GDP) របស់ប្រទេស។ ការផលិតជួយជម្រុញការច្នៃប្រឌិត និងការរីកចម្រើនបច្ចេកវិទ្យា ព្រោះក្រុមហ៊ុនត្រូវវិនិយោគលើម៉ាស៊ីនឧបករណ៍ ការស្វ័យប្រវត្តិការ និងវិធីសាស្ត្រផលិតថ្មីៗ ដើម្បីរក្សាការប្រកួតប្រជែង។ វាក៏ជួយបង្កើនការអភិវឌ្ឍវិស័យពាក់ព័ន្ធដូចជាការដឹកជញ្ជូន ការលក់រាយ និងភ្នាក់ងារដឹកចេញទំនិញ ដោយបង្កើតអត្ថប្រយោជន៍ជាច្រើនទៅកាន់វិស័យផ្សេងទៀត។ លើសពីនេះ ការផលិតជួយកាត់បន្ថយការពឹងផ្អែកលើការនាំចូល ដោយផលិតទំនិញនៅក្នុងប្រទេសខ្លួនឯង ដែលអាចធ្វើឱ្យសមតុល្យពាណិជ្ជកម្មប្រសើរឡើង និងបង្កើនសមត្ថភាពឯករាជ្យជាតិក្នុងវិស័យសេដ្ឋកិច្ច។ ការផលិតក៏អាចធ្វើឱ្យតម្លៃទំនិញថោកជាង ដោយសារការផលិតច្រើនក្នុងពេលតែមួយ និងធានាផលិតផលដែលមានគុណភាពខ្ពស់ និងមានស្តង់ដារ។ សរុបមក ការផលិតគឺជាម៉ាស៊ីនសំខាន់មួយសម្រាប់ការបង្កើតការងារ ការច្នៃប្រឌិត ការអភិវឌ្ឍសេដ្ឋកិច្ច និងការកែលម្អជីវភាពរបស់ប្រជាជន[14]។

---

13 GeeksforGeeks. (2024, February 29). លក្ខណៈនៃការគ្រប់គ្រង. Retrieved August, 15 2025, from https://www.geeksforgeeks.org/production-function-meaning-features-and-types/

14 Makers Row. Shruti Ghosh. (2024, July 19). *អត្ថប្រយោជន៍នៃការផលិត*. Retrieved August, 30 2025, from https://makersrow.com/blog/top-10-benefits-of-keeping-your-manufacturing-local/

# ជំពូកទី៣

# ប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិតរបស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)

## ៣.១ ស្ថានភាពទូទៅរបស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)

### ៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន

ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា) Aprati Foods (Cambodia) Ltd. (AFC) គឺជាអតីតក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន American Licorice (ALC) ដែលមានជំនាញក្នុងការផលិតស្ករគ្រាប់។ ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៅឆ្នាំ២០១៣ និងបានបង្កើតរោងចក្រ នៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (PPSEZ) នៅឆ្នាំ២០១៦។ AFC ផលិតស្ករគ្រាប់ចំនួន ៣ ម៉ាកសញ្ញាសម្រាប់ទីផ្សារកម្ពុជាគឺ Mocati, Aprati, និង Frutati។




- សម្រាប់ម៉ាកស្ករគ្រាប់ Mocati មានរសជាតិចំនួន៤គឺ៖
  - រសជាតិតែផ្កាកុលាប
  - រសជាតិតែផ្លែគូលែន
  - រសជាតិតែផ្លែប៉េស
  - រសជាតិសូកូឡា។
- សម្រាប់ម៉ាកស្ករគ្រាប់ Aprati ត្រូវបានបែងចែកជា២ប្រភេទគឺ៖
  - Aprati Milk Tablet
  - ស្ករគ្រាប់រឹងរសជាតិ ជីរអង្កាម។
- សម្រាប់ Frutati ត្រូវបានបែងចែកជា២ប្រភេទ ដោយមានស្ករគ្រាប់រឹង និងចាហួយស្វិត៖
  - សម្រាប់ស្ករគ្រាប់រឹងមាន៖ រសជាតិទំពាំងបាយជូរ, រសជាតិម្នាស់ទឹកឃ្មុំ, រសជាតិព្រីង, រសជាតិអម្ពិលហឹរ, រសជាតិត្របែកអំបិលម្ទេស, រសជាតិគូលែនព្រៃអំបិលម្ទេស

- សម្រាប់ចាហួយស្វិតមាន៖ មានរសជាតិក្រូចពោធិ៍សាត់, រសជាតិត្រប៉ែក, រសជាតិគូលែន, រសជាតិអម្ពិលផ្អែម, និងរសជាតិព្រីង។
- AFC ក៏បាននាំចេញស្ករគ្រាប់ផលិតផលទៅសហរដ្ឋអាមេរិកក្រោមម៉ាក Mocati និង Frutati។




**៣.១.២ បេសកកម្ម ទស្សនវិស័យ និងគោលដៅរបស់ក្រុមហ៊ុន**

បេសកកម្មរបស់ក្រុមហ៊ុន AFC ចង់ចូលរួមយ៉ាងសកម្មក្នុងវង្វង់នៃការពិសោធន៍យ៉ាងឆាប់រហ័ស និងការដោះស្រាយបញ្ហា ដែលនាំមកនូវការរៀនសូត្រយូរអង្វែង ការកែលម្អឥតឈប់ឈរ និងភាពជោគជ័យ។ យើងកំពុងសិក្សា និងកែលម្អឱ្យប្រសើរឡើង។ យើងរួមចំណែកដល់សុខុមាលភាពនៃសហគមន៍របស់យើង ដោយអនុវត្តជាក្រុមហ៊ុនដែលមានការទទួលខុសត្រូវខាងសង្គម និងបរិស្ថាន។

ទស្សនវិស័យរបស់ក្រុមហ៊ុនគឺ AFC ចង់ក្លាយជាក្រុមហ៊ុនដែលអនុវត្តការងារល្អ។ យើងចង់បង្កើតវប្បធម៌នៃការដោះស្រាយបញ្ហា និងការកែលម្អឱ្យប្រសើរឡើងជាបន្តបន្ទាប់ឥតឈប់ឈរ។

គោលដៅរបស់ក្រុមហ៊ុនគឺ AFC ចង់បង្កើតឱកាសបន្ថែមជាច្រើនដើម្បីបង្កើនភាពរីករាយកាន់តែច្រើនសម្រាប់ អ្នកបរិភោគ អតិថិជន បុគ្គលិក និងសហគមន៍ របស់យើង។

**៣.១.៣ រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន**



## ៣.២ យុទ្ធសាស្ត្រនៃការគ្រប់គ្រងដំណើរការផលិតឱ្យមានប្រសិទ្ធភាពរបស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)

### ៣.២.១ ដំណើរការនៃការផលិត

#### ក. ការរៀបចំវត្ថុធាតុដើម

- ជំហានទី១: ទទួលវត្ថុធាតុដើមមានដូចខាងក្រោម៖ សារធាតុកាហ្វេ, រសជាតិ (flavor), សារធាតុ Emulsifiers, ប្រេងបន្លែ, អំបិល, ស្ករ និងស៊ីរ៉ូគ្លុយកូស ត្រូវបានដឹកជញ្ជូនមកពីអ្នកផ្គត់ផ្គង់ក្នុងស្រុក និងក្រៅស្រុក។
- ជំហានទី២: ទទួលសម្ភារៈវេចខ្ចប់៖ សម្ភារៈវេចខ្ចប់ត្រូវបានដឹកជញ្ជូនពីអ្នកផ្គត់ផ្គង់ក្នុងស្រុក និងក្រៅស្រុក តាមអាកាស, ទូក ឬដឹកជញ្ជូនតាមផ្លូវគោក និងមកដល់គោលដៅតាមរថយន្តនៅសីតុណ្ហភាពធម្មតា។
- ជំហានទី៣: ទឹកផ្គត់ផ្គង់ពីទីក្រុងត្រូវបានផ្ទុកក្នុងធុងទឹកនៅខាងក្រៅអគារផលិត។
- ជំហានទី៤: ការរក្សាទុកក្នុងសីតុណ្ហភាពធម្មតា៖ ស្ករ, អំបិល, ប្រេងបន្លែ និងស៊ីរ៉ូគ្លុយកូស ត្រូវបានផ្ទុកក្នុងផ្លាស្ទិចក្នុងឃ្លាំងដែលមានសីតុណ្ហភាពធម្មតា។
- ជំហានទី៥: ការរក្សាទុកក្នុងបន្ទប់ត្រជាក់៖ រសជាតិ (flavor) និងសារធាតុ Emulsifiers ត្រូវបានផ្ទុកលើធ្នើដែកក្នុងបន្ទប់ត្រជាក់ (ក្រោម 25°C)។
- ជំហានទី៦: ការរក្សាទុកសម្ភារៈវេចខ្ចប់៖ ផ្ទុកសម្ភារៈនៅលើថាសផ្លាស្ទិចក្នុងឃ្លាំងនៅ សីតុណ្ហភាពធម្មតា។
- ជំហានទី៧:ប្រព័ន្ធ RO៖ ទឹកពីទីក្រុងត្រូវបានចម្រាញ់តាមប្រព័ន្ធ RO ហើយផ្ទុកក្នុងធុងទឹក។
- ជំហានទី៨: សម្ភារៈវេចខ្ចប់ត្រូវបានផ្ទុកក្នុងបន្ទប់ត្រជាក់ (ក្រោម 25°C) រយៈពេលមួយសប្តាហ៍មុនពេលប្រើប្រាស់។
- ជំហានទី៩: ផ្ទេរទៅបន្ទប់ស្តុកទុកគ្រឿងផ្សំ៖ អំបិល ស្ករ និង ស៊ីរ៉ូគ្លុយកូស ត្រូវបានផ្ទេរទៅក្នុងបន្ទប់ស្តុកទុកគ្រឿងផ្សំ។
- ជំហានទី១០: ការថ្លឹង៖ រសជាតិ (flavor), អំបិល និងសារធាតុ Emulsifiers ត្រូវបានថ្លឹងដោយជញ្ជីងអេឡិចត្រូនិច។

- ជំហានទី១១: ការច្រោះស្ករ៖ ស្ករត្រូវបានច្រោះតាមតម្រងសំណាញ់ដែក (pore size 5.4 – 5.5 mm) ដើម្បីយកកាកសំណល់ចេញ។
- ជំហានទី១២: ការលាយបឋម៖ សារជាតុ Emulsifiers (lecithin) និងប្រេងបន្លែ ត្រូវបានលាយដោយដៃ (Homogenizing)។
- ជំហានទី១៣: ការថ្លឹង៖ ថ្លឹងស្ករ និងស៊ីរ៉ូគ្លុយកូស សម្រាប់ផលិតស្ករគ្រាប់។
- ជំហានទី១៤: ការលាយពណ៌បឋម៖ ពណ៌ត្រូវបានលាយជាមុនជាមួយទឹក RO មុនបន្ថែមទៅការលាយជាមួយគ្រឿងផ្សំផ្សេងទៀត។
- ជំហានទី១៥: លាយគ្រឿងផ្សំ៖ ស្ករ ស៊ីរ៉ូគ្លុយកូស និងទឹកត្រូវបានលាយក្នុងធុង ដោយប្រើសីតុណ្ហភាព (85°C ដល់ 90°C) ហើយបន្ថែមប្រេងបន្លែ និងសារជាតុ Emulsifiers (lecithin) កូរ 4–8 នាទី មុនដាក់ចូល buffer tank។
- ជំហានទី១៦: ច្រោះជាលើកទី២៖ ស្ករត្រូវបានច្រោះតាមតម្រងសំណាញ់ដែក (10 mesh = 2mm) ដើម្បីយកកាកសំណល់ ដែលមានទំហំ 2mm ចេញ។
- ជំហានទី១៧: ការប្រើដែកឆក់៖ ការប្រើដែកឆក់បន្ទាប់ពីការច្រោះ ដើម្បីយកជាតុដែកចេញ។ កម្លាំងដែកឆក់គឺ 53 ± 10 N។
- ជំហានទី១៨: Buffer Tank៖ Buffer Tank ជាធុងផ្ទុកដូចជា ស្ករ, ស៊ីរ៉ូគ្លុយកូស, ទឹក, ប្រេងបន្លែ និងសារជាតុ Emulsifiers ដែលត្រូវបានលាយមុនចូលទៅក្នុង Pre-cooker និង Cooker។

### ខ. ដំណើរការផលិត

- ជំហានទី១៩: តម្រង (Strainer)៖ Slurry នឹងឆ្លងកាត់បំពង់បញ្ជូនដែលមានតម្រង។ តម្រងនេះមានមុខងារ ដកយកអ្វីៗដែលមានទំហំធំជាង ១មម ចេញ។
- ជំហានទី២០:ការលាយដោយប្រើ Static Mixer៖ ជាតិពារនឹងត្រូវលាយជាមួយរសជាតិ មុននឹងទៅ Pre-cooker។ វាលាយសារជាតុពារពីរចូលគ្នាតាមបំពង់តែមួយ។ ជំហាននេះមិនបានអនុវត្តសម្រាប់ផលិតផលទាំងអស់ទេនោះទេ។
- ជំហានទី២១: Pre-cooker៖ ជាតិពារត្រូវបានដុតកំដៅក្នុងកម្ដៅបំពង់ ដើម្បីឱ្យសីតុណ្ហភាពទៅដល់តាមគោលដៅ មុននឹងបញ្ជូនទៅម៉ាស៊ីនដែលមានក្នុងសម្ពាធទាប (vacuum cooker)។
- ជំហានទី២២: ម៉ាស៊ីនដែលមានសម្ពាធទាប (Vacuum Cooker)៖ នៅជំហាននេះ សារជាតុពារនឹងត្រូវបានដុតកំដៅដោយនៅសីតុណ្ហភាព ≥ 133 ℃ និងសម្ពាធទាបប្រហែល -42cm/Hg ដើម្បីដកយកសំណើមចេញភាគច្រើនជាជាតិពារ។
- ជំហានទី២៣: Slurry Pipe Line៖ សារជាតុពារចុងក្រោយនឹងត្រូវបញ្ជូនតាមបំពង់ដែក អ៊ីណុកដែលមានស្រទាប់កំដៅពីខាងក្រៅ ទៅកាន់ Depositing hopper សម្រាប់បញ្ជូនចូលទៅក្នុងពុម្ព។
- ជំហានទី២៤៖ In-line mixer៖ រសជាតិក៏ត្រូវបានបន្ថែមតាមរយៈឧបករណ៍ In-line mixer។ នៅជំហាននេះ សារជាតុពារចុងក្រោយនឹងជួបប្រទះនឹងរសជាតិដែលបានបាញ់ចេញពីម៉ាស៊ីនមុនពេលទៅកាន់ធុងបញ្ជូនទៅក្នុងពុម្ព។

- ជំហានទី២៥: ធុងបញ្ចូន (Depositing Hopper)៖ បរិមាណសារធាតុរាវដែលមានរសជាតិត្រូវបានរក្សាទុកក្នុងធុងបញ្ចូន។ វាត្រូវបានដុតកំដៅដែលមានសីតុណ្ហភាព នៅចន្លោះ 110-135°C។ វាបានធានាថាសារធាតុរាវមិនត្រូវកកមុនពេលបញ្ចូលទៅក្នុងពុម្ព។
- ជំហានទី២៦: ការបញ្ចូលពុម្ព និងដកចេញពីពុម្ព (Mounding and Demolding)៖ ជាតិរាវត្រូវបានបញ្ចូលទៅក្នុងពុម្ពដែក មានរាងតាមពុម្ព។ នៅពេលបញ្ចូលទៅក្នុងពុម្ព បុគ្គលិកនឹងសង្កេតមើលពណ៌ និងរូបរាង ដើម្បីធ្វើការបញ្ជាក់ថាផលិតផលស្ថិតក្នុងស្តង់ដារ។ បើវាខុសស្តង់ដារ ស្ករគ្រាប់នោះនឹងត្រូវបោះចោល។ ស្ករគ្រាប់នឹងត្រូវផ្ទេរពីពុម្ព ដោយដឹកជញ្ជូនពីតំបន់ក្តៅទៅតំបន់ត្រជាក់។
- ជំហានទី២៧: Discharging Tray៖ នៅក្នុងជំហាននេះ ស្ករគ្រាប់ខូច ឬមានរាងខុសៗអាចធ្លាក់ចេញតាមរន្ធខ្សែ និងត្រូវបានបោះចោលនៅចុងបញ្ចប់នៃផលិតកម្ម។
- ជំហានទី២៨: ខ្សែដឹកជញ្ជូន៖ ខ្សែដឹកជញ្ជូនប្លាស្ទិកពណ៌ស នឹងផ្ទេរស្ករគ្រាប់ទៅម៉ាស៊ីនខ្ចប់ ដោយឆ្លងកាត់ឧបករណ៍ស្វែងរកជាតុដែក។
- ជំហានទី២៩: ម៉ាស៊ីនរកសារធាតុដែក (Metal Detector)៖ ស្ករគ្រាប់នឹងឆ្លងកាត់ម៉ាស៊ីនរកសារធាតុដែក ដើម្បីបំបាត់គ្រោះថ្នាក់។ ស្ករគ្រាប់ដែលមានសារធាតុដែកនឹងត្រូវបោះចោល ចំណែកឯស្ករគ្រាប់ដែលគ្មានការបំពុលនឹងត្រូវបន្តទៅកាន់ដំណាក់កាលចុងក្រោយ។
- ជំហានទី៣០: ខ្សែដឹកជញ្ជូន ២៖ ខ្សែដឹកជញ្ជូនពណ៌សនឹងដឹកជញ្ជូនស្ករគ្រាប់ពីម៉ាស៊ីនរកជាតុដែកទៅឧបករណ៍វិចខ្ចប់។
- ជំហានទី៣១: ការវេចខ្ចប់ (Wrapping)៖ ស្ករគ្រាប់ត្រូវបានវេចខ្ចប់។



### គ. ដំណើរការវេចខ្ចប់ផលិតផល

ដំណើរការវេចខ្ចប់ផលិតផលរបស់ក្រុមហ៊ុនផលិតមានសារៈសំខាន់ ក្នុងការថែរក្សាគុណភាព និងធានាថាផលិតផលអាចដឹកជញ្ជូនដល់ដៃអតិថិជនបានយ៉ាងសុវត្ថិភាព។ ដំណើរការនៃការវេចខ្ចប់មាន ៦ជំហាន៖

- **ការត្រួតពិនិត្យគុណភាពផលិតផល (Quality Control)៖** មុនពេលវេចខ្ចប់ ផលិតផលត្រូវបានត្រួតពិនិត្យឱ្យប្រាកដថាមានគុណភាពត្រឹមត្រូវមិនមានការខូចខាត ឬមានកម្រិតខុសពីស្តង់ដា។
- **ការជ្រើសរើសវត្ថុធាតុវេចខ្ចប់ (Packaging Materials Selection)៖** ការជ្រើសរើសប្រភេទក្រដាសប្រអប់ ឬវត្ថុផ្សេងៗសមស្របសម្រាប់ការពារ និងបង្ហាញផលិតផល។
- **ការវេចខ្ចប់ (Packaging)៖** ការវេចខ្ចប់ផ្ទាល់ទៅលើផលិតផល ដោយដាក់ចូលទៅក្នុងប្រអប់ កែវ ឬវត្ថុណាមួយដើម្បីងាយស្រួលក្នុងការដឹកជញ្ជូន និងរក្សាទុក។
- **ស្លាកសញ្ញានិងព័ត៌មានផលិតផល (Labeling)៖** ការបន្ថែមស្លាកសញ្ញា រួមមានព័ត៌មានសំខាន់ៗដូចជា ឈ្មោះផលិតផល កាលបរិច្ឆេទ (ថ្ងៃផលិត និង ផុតកំណត់) កូដផលិតផល និង QR/Barcode។
- **ការត្រួតពិនិត្យចុងក្រោយ (Final Inspection)៖** បញ្ជាក់ថាផលិតផលទាំងអស់វេចខ្ចប់បានត្រឹមត្រូវ និងមានត្រារបស់ក្រុមហ៊ុន មុនពេលដឹកចេញពីរោងចក្រ។
- **ដឹកជញ្ជូន (Distribution)៖** ផលិតផលដែលវេចខ្ចប់រួចត្រូវបានដឹកទៅឃ្លាំង ឬបញ្ជូនទៅអតិថិជនតាមរយៈមធ្យោបាយដឹកជញ្ជូនផ្សេងៗ។



### ឃ. ការត្រួតពិនិត្យគុណភាពផលិតផល

ដើម្បីឱ្យគុណភាពផលិតផលមានគុណភាពល្អ និងត្រឹមត្រូវ ពោលគឺត្រូវកំណត់តាមចំណុចសំខាន់ៗដូចខាងក្រោម៖

- **ការកំណត់ស្តង់ដារ (Setting standards)៖** កំណត់លក្ខណៈបច្ចេកទេស ឬស្តង់ដាដែលផលិតផលត្រូវតែបំពេញដូចជា ទំហំ ទម្ងន់ ពណ៌ សម្បុរ ប្រភេទវត្ថុធាតុដើម។ល។

- **ការត្រួតពិនិត្យវត្ថុធាតុដើម (In-process Inspection)៖** ត្រួតពិនិត្យគុណភាពផលិតផលនៅពេលផលិត ដើម្បីរកថាមានកំហុស ឬមួយក៏អត់ដើម្បីកែសម្រួលឱ្យទាន់ពេលវេលាភ្លាមៗ។
- **ការត្រួតពិនិត្យចុងក្រោយ (Final Inspection)៖** ពិនិត្យផលិតផលចុងក្រោយមុននឹងដាក់ចេញលក់ឬប្រើប្រាស់ដើម្បីធានាថាផលិតផលមានគុណភាពល្អមិនមានកំហុស។
- **ការបញ្ជាក់ និងរាយការណ៍ (Verification & Reporting)៖** កំណត់ត្រា និងរាយការណ៍លទ្ធផលនៃការត្រួតពិនិត្យ ដើម្បីអាចតាមដានកែសម្រួលឬធ្វើការកែសម្រួលក្រោយបាន។
- **ការកែលម្អជាប្រចាំ (Continuous Improvement)៖** ប្រើលទ្ធផលនៃការត្រួតពិនិត្យដើម្បីធ្វើការកែលម្អដំណើរការផលិតឱ្យបានល្អជាងមុន។

### ង. ការថែទាំ និងការស្តុកទុកផលិតផលសម្រេច

ខាងក្រោមនេះជាវិធីសាស្ត្រក្នុងការថែទាំនិងការស្តុកទុកផលិតផលសម្រេច៖

**១.ការបែងចែកទីតាំងស្តុក**

- បែងចែកទីតាំងស្តុកឱ្យច្បាស់
- ប្រើប្រព័ន្ធ Labeling ឬ Barcode ដើម្បីងាយស្រួលក្នុងការរកទំនិញ។

**២.ការសម្អាតនិងការថែទាំទំនិញ**

- ត្រួតពិនិត្យសភាពខាងក្រៅ (ការខូចខាត ការធ្វើឱ្យបាក់បែកជាដើម)
- ទុកផលិតផលក្នុងបរិស្ថានសមស្រប (សំណើម សីតុណ្ហភាព ពន្លឺ)
- ប្រើ FIFO (First in, First Out) ប្រសិនបើជាផលិតផលដែលមាន កាលបរិច្ឆេទផុតកំណត់ ប៉ុន្តែសម្រាប់ក្រុមហ៊ុនផ្ទាល់នៅមានកម្រិតក្នុងការគ្រប់គ្រងប្រព័ន្ធសារពើភ័ណ្ឌ FIFO ដែលជាវិធីសាស្ត្រប្រើប្រាស់ក្នុងការបង្ការ ការផុតកំណត់ និងកាត់បន្ថយថ្លៃដើម។

**៣.ប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងស្តុក**

- កំណត់ការចូលចេញផលិតផល
- ពិនិត្យមើលសារពើភ័ណ្ឌជាទៀងទាត់
- បង្កើតរបាយការណ៍ស្តុកជាប្រចាំ។

**៤.សុវត្ថិភាពនិងរបាយការណ៍បរិស្ថាន**

- ទុកផលិតផលឱ្យឆ្ងាយពី សារធាតុគីមីគ្រោះថ្នាក់
- បង្រៀនបុគ្គលិកឱ្យដឹងពីវិធីដោះដូរទំនិញដោយប្រុងប្រយ័ត្ន។

## ៣.២.២ យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងដំណើរការផលិតឱ្យមានប្រសិទ្ធភាព

### ក. ការធ្វើផែនការនៃដំណើរការផលិត

ការធ្វើផែនការនៃដំណើរការផលិត គឺជាដំណាក់កាលសំខាន់សម្រាប់ក្រុមហ៊ុនអេប្រាធី ហ្វ៊ូដ (ខេមបូឌា) ដើម្បីធានាថាការផលិតប្រព្រឹត្តទៅយ៉ាងមានប្រសិទ្ធភាព និងអាចបំពេញតម្រូវការរបស់ទីផ្សារ។ ក្រុមហ៊ុនបានធ្វើផែនការនៃដំណើរការផលិតទៅតាមដំណាក់កាលដោយ បានធ្វើការវិភាគនិងព្យាករណ៍អំពីតម្រូវការផលិតផលក្នុងពេលអនាគត ដើម្បីដឹងអំពីចំនួនផលិតផលដែលត្រូវផលិត។ ក្រុមហ៊ុនបានកំណត់អំពីគោលបំណងនៃផលិតកម្មដោយផ្តោតទៅលើ ចំនួន និងគុណភាពនៃផលិតផល។ ក្រុមហ៊ុនបានធ្វើការរៀបចំនូវ

ធនធាន រួមមានវត្ថុធាតុដើម ឧបករណ៍ម៉ាស៊ីន ដើម្បីប្រើប្រាស់ក្នុងដំណើរការផលិត។ ក្រុមហ៊ុនបានធ្វើការរៀបចំដំណើរការនៃការផលិត ដោយធ្វើការបែងចែក ការផលិត ចាប់ពីការរៀបចំវត្ថុធាតុដើម ដំណើរការផលិតដល់ការវេចខ្ចប់និងចែកចាយ។ ក្រុមហ៊ុនបានធ្វើការកំណត់ពេលវេលា ដោយគ្រប់គ្រងពេលវេលាក្នុងដំណាក់កាល នីមួយៗឱ្យមានប្រសិទ្ធ ដើម្បីធានាថាការផលិតអាចដំណើរការតាមគម្រោងដែលបានកំណត់។ ក្រុមហ៊ុនបានធ្វើការត្រួតពិនិត្យនិងតាមដានអំពី ដំណើរការផលិតជាប្រចាំ ដើម្បីស្វែងរកបញ្ហា និងធ្វើការកែសម្រួលឱ្យទាន់ពេលវេលា។ ជាចុងក្រោយក្រុមហ៊ុនបានធ្វើការបោះពុម្ពចេញជារបាយការណ៍ និងធ្វើការវាយតម្លៃ លើផលិតផលដែលបានផលិត និងការរៀបចំផែនការបន្តសម្រាប់ផែនការនាពេលអនាគត។

### ខ. ការគ្រប់គ្រងវត្ថុធាតុដើមឱ្យមានប្រសិទ្ធភាព

ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា) Aprati Foods (Cambodia) Ltd. បានធ្វើការគ្រប់គ្រងវត្ថុធាតុដើមឱ្យមានប្រសិទ្ធភាពទៅតាមដំណាក់កាលដែលបានកំណត់៖

១. នៅពេលដែលវត្ថុធាតុដើមត្រូវបានដឹកជញ្ជូនដល់ឃ្លាំងស្តុកវត្ថុធាតុដើម ផ្នែកនីមួយៗ ដែលមានការពាក់ព័ន្ធនឹងការត្រួតពិនិត្យវត្ថុធាតុដើម ត្រូវមកត្រួតពិនិត្យទៅលើផ្នែកគុណភាព និងបរិមាណ។ ឧទាហរណ៍៖ គ្រប់វត្ថុធាតុដើមត្រូវមកភ្ជាប់ជាមួយនឹងឯកសារបញ្ជាក់គុណភាព ហើយក្រុមហ៊ុនក៏មានអ្នកជំនាញខាងផ្នែកត្រួតពិនិត្យគុណភាពសម្រាប់វាយតម្លៃទៅលើវត្ថុធាតុដើមនោះពិតជាសមស្របទៅនឹងឯកសារដែលបានភ្ជាប់ជាមួយឬអត់។

២. ការត្រួតពិនិត្យសន្និធិវត្ថុធាតុដើម ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា) បានបែងចែកស្តុកវត្ថុធាតុដើមជា២ផ្នែកគឺ ផ្នែកស្តុកវត្ថុធាតុដើមវិចខ្ចប់ដូចជាកេសនិងថង់ប្លាស្ទិចសំរាប់វិចខ្ចប់ និងផ្នែកស្តុកវត្ថុធាតុដើមគ្រឿងផ្សំដូចជា រសជាតិ សារធាតុ Emulsifier ប្រេងបន្លែ អំបិល ស្ករស និងទឹកស៊ីរ៉ូស្ករ។ ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា) បែងចែកការគ្រប់គ្រងសន្និធិវត្ថុធាតុដើមជា៣គឺ៖

- **ការកំណត់ចំនួនសំរាប់ស្តុកវត្ថុធាតុដើម**

- កន្លែងស្តុករសជាតិ អាចស្តុកជាអតិបរមា ០,៥ តោន
- កន្លែងស្តុកសារជាតុ Emulsifier អាចស្តុកជាអតិបរមា ០,២ តោន
- កន្លែងស្តុកប្រេងបន្លែ អាចស្តុកជាអតិបរមា ០,៥ តោន
- កន្លែងស្តុកអំបិល អាចស្តុកជាអតិបរមា ១ តោន
- កន្លែងស្តុកស្ករស អាចស្តុកបានជាអតិបរមា ១០ តោន
- កន្លែងស្តុកទឹកស៊ីរ៉ូស្ករអាចស្តុក ជាអតិបរមា ១០ តោន។

- **រក្សាឱ្យបាននូវគុណភាពសម្រាប់ស្តុកវត្ថុធាតុដើមនៅក្នុងឃ្លាំង**

ក្រុមហ៊ុនបានស្តុកវត្ថុធាតុដើមទៅតាមកន្លែងដែលបានកំណត់ដូចជា៖

- ដាក់វត្ថុធាតុដើមតាមទីតាំងដែលបានកំណត់
- កំណត់លំហរផ្លូវដើរនៅតាមកន្លែងស្តុកវត្ថុធាតុដើម
- ដាក់បាឡែតទ្រវត្ថុធាតុដើមដើម្បីការពារវត្ថុធាតុដើមពីសត្វចង្រៃ
- សំអាតកន្លែងស្តុកវត្ថុធាតុដើមមិនឱ្យមានសំណើម ធូលី និងសត្វចង្រៃ

- រក្សាសីតុណ្ហភាពត្រជាក់ចំពោះវត្ថុធាតុដើមណាដែលត្រូវការភាពត្រជាក់ដើម្បីរក្សាទុក។

- **ការរក្សាបរិមាណស្តុកវត្ថុធាតុដើមនៅក្នុងឃ្លាំងឱ្យបានត្រឹមត្រូវ**

អ្នកគ្រប់គ្រងស្តុកនៅក្នុងក្រុមហ៊ុនបានប្រើវិធីសាស្ត្រដើម្បីគ្រប់គ្រងវត្ថុធាតុដើមឱ្យបានត្រឹមត្រូវដូចខាងក្រោម៖

- ចំពោះរសជាតិ ដែលមាននៅក្នុងឃ្លាំងសល់ត្រឹមតែ ០.១ ទៅ ០.២ តោន អ្នកគ្រប់គ្រងស្តុកត្រូវបញ្ជាទិញបន្ថែមឱ្យគ្រប់ ០.៥ តោន វិញហើយការបញ្ជាទិញនោះទៀតសោតត្រូវកម្មង់ទុក ៣០ ទៅ ៤៥ ថ្ងៃមុន។
- ចំពោះសារធាតុ Emulsifier ដែលមាននៅក្នុងឃ្លាំងសល់ត្រឹមតែ ០.០៦ តោន អ្នកគ្រប់គ្រងស្តុកត្រូវបញ្ជាទិញបន្ថែមឱ្យគ្រប់ ០.២ តោន វិញហើយការបញ្ជាទិញនោះវិញទៀតសោតត្រូវកម្មង់ទុក ៣០ ទៅ ៤៥ ថ្ងៃមុន។
- ចំពោះប្រេងបន្លែ ដែលមាននៅក្នុងឃ្លាំងនៅសល់ត្រឹមតែ ០.១ ទៅ ០.២ តោន អ្នកគ្រប់គ្រងស្តុកត្រូវបញ្ជាទិញបន្ថែមឱ្យគ្រប់ ០.៥ តោន វិញហើយការបញ្ជាទិញនោះទៀតសោតត្រូវកម្មង់ ទុក ៣០ ទៅ ៤៥ ថ្ងៃមុន។
- ចំពោះអំបិល ដែលមាននៅក្នុងឃ្លាំងសល់ត្រឹមតែ ០.៣ តោន អ្នកគ្រប់គ្រងស្តុកត្រូវបញ្ជាទិញបន្ថែមឱ្យគ្រប់ ១ តោន វិញហើយការបញ្ជាទិញនោះវិញទៀតសោតត្រូវកម្មង់ទុក ៣០ ទៅ ៤៥ ថ្ងៃមុន។
- ចំពោះស្ករស ដែលមាននៅក្នុងឃ្លាំងសល់ត្រឹមតែ ៣ តោន អ្នកគ្រប់គ្រងស្តុកត្រូវបញ្ជាទិញបន្ថែមឱ្យគ្រប់ ១០ តោន វិញហើយការបញ្ជាទិញនោះវិញទៀតសោតត្រូវកម្មង់ទុក ៣០ ទៅ ៤៥ ថ្ងៃមុន។
- ចំពោះទឹកស៊ីរ៉ូស្ករ ដែលមាននៅក្នុងឃ្លាំងសល់ត្រឹមតែ ៣ តោន អ្នកគ្រប់គ្រងស្តុកត្រូវបញ្ជាទិញបន្ថែមឱ្យគ្រប់ ១០ តោន វិញហើយការបញ្ជាទិញនោះវិញទៀតសោតត្រូវកម្មង់ទុក ៣០ ទៅ ៤៥ ថ្ងៃមុន។

### គ. ការគ្រប់គ្រង និងបែងចែកកម្លាំងពលកម្ម

ការគ្រប់គ្រង និងបែងចែកកម្លាំងពលកម្មនៅក្នុងក្រុមហ៊ុនផលិតស្ករគ្រាប់ Aprati Foods គឺជាផ្នែកសំខាន់ក្នុងការធានាថាក្រុមហ៊ុនអាចប្រតិបត្តិការផលិតបានយ៉ាងមានប្រសិទ្ធភាព និងកាត់បន្ថយចំណាយ។ កម្លាំងពលកម្មក្នុងវិស័យផលិតស្ករគ្រាប់គឺជាប្រភពសំខាន់នៃការផលិត ដូចនេះការគ្រប់គ្រងទិន្នន័យ និងបែងចែកការងារយ៉ាងត្រឹមត្រូវគឺមានអត្ថប្រយោជន៍ក្នុងការបង្កើនផលិតភាព និងគុណភាពផលិតផល។

#### ១. ការគ្រប់គ្រងកម្លាំងពលកម្មតាមផ្នែកការងារ

- **បែងចែកការងារតាមជំនាញ**: ក្រុមហ៊ុន Aprati Foods ប្រើប្រាស់វិធីសាស្ត្របែងចែកការងារជាសមាសភាគ ដើម្បីធានាថា ការងារដែលតម្រូវឱ្យមានជំនាញខ្ពស់ និងត្រូវការពិចារណាច្រើន គឺត្រូវតែទាមទារឱ្យមានបុគ្គលិកដែលមានជំនាញខ្ពស់មកកាន់ការ។

- **ការប្រើប្រាស់កម្លាំងពលកម្មដែលមានជំនាញ**: ក្រុមហ៊ុនត្រូវការបុគ្គលិកដែលមានជំនាញក្នុងវិស័យជាក់លាក់ ដូចជា វិស្វកម្មផលិតកម្ម និងការត្រួតពិនិត្យគុណភាព។ ក្រុមហ៊ុនប្រើប្រាស់អ្នកបច្ចេកទេសដែលមានបទពិសោធន៍ក្នុងការប្រើប្រាស់បច្ចេកវិទ្យាទំនើបសម្រាប់ការផលិត។

**២. ការគ្រប់គ្រងពេលវេលា**

- **ការគ្រប់គ្រងម៉ោងការងារ**: ក្រុមហ៊ុន Aprati Foods មានប្រព័ន្ធត្រួតពិនិត្យម៉ោងការងារដើម្បីធានាថាបុគ្គលិកគ្រប់គ្រងម៉ោងបានយ៉ាងត្រឹមត្រូវ និងមានប្រសិទ្ធភាពក្នុងការចំណាយម៉ោងចំពោះការងារ។
- **បំពេញតម្រូវការផលិតតាមកម្រិត**: ក្រុមហ៊ុនផ្តល់នូវការបែងចែកម៉ោងការងារផ្អែកលើតម្រូវការផលិតនៅរៀងរាល់ពេល ដើម្បីធានាថាមានកម្លាំងពលកម្មគ្រប់គ្រាន់ និងត្រូវតាមដំណើរការផលិតប្រកបដោយប្រសិទ្ធភាព។

**៣. ការបណ្តុះបណ្តាល និងអភិវឌ្ឍកម្លាំងពលកម្ម**

- **កម្មវិធីបណ្តុះបណ្តាល**: Aprati Foods មានកម្មវិធីបណ្តុះបណ្តាល ដើម្បីបង្កើនជំនាញ និងភាពរួសរាន់ក្នុងការងារផលិតកម្ម។ ក្រុមហ៊ុនបណ្តុះបណ្តាលឱ្យកម្លាំងពលកម្មមានភាពរីកចម្រើនទាំងនៅក្នុងបច្ចេកទេសនិងបច្ចេកវិទ្យាផលិត ប៉ុន្តែក្នុងករណីជាក់ស្តែងនៅក្នុងស្ថានភាពក្រុមហ៊ុននៅមានកម្រិតនៅក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ក្នុងការបង្កើនល្បឿននៃការផលិត និងកាត់បន្ថយកម្លាំងពលកម្ម។
- **ការបង្កើតមូលដ្ឋានសម្រាប់ការអភិវឌ្ឍន៍បុគ្គលិក**: ក្រុមហ៊ុនបានបង្កើតវគ្គបណ្តុះបណ្តាលដែលមានការបង្កើតតាមការសិក្សាផ្ទាល់ខ្លួននិងការបង្ហាញបច្ចេកទេសថ្មីៗដើម្បីជួយពង្រឹងសមត្ថភាព។

**៤. ការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្ម**

- **ការពិនិត្យចំពោះប្រសិទ្ធភាពការងារ**: ក្រុមហ៊ុនមានប្រព័ន្ធដូចជា KPI (Key Performance Indicator) ដើម្បីត្រួតពិនិត្យសមត្ថភាពការងារនៃបុគ្គលិក។ ការពិនិត្យលទ្ធផលនិងការលើកស្ទួយជំនាញដែលជាគន្លឹះសំខាន់ក្នុងការគ្រប់គ្រង។
- **ការបំពាក់បរិក្ខារក្នុងដំណើរការផលិតកម្ម**: ក្រុមហ៊ុនសម្រេចចិត្តផ្តល់ជូនឧបករណ៍និងធនធានដែលអាចធានាថា កម្មករអាចធ្វើការបានល្អនៅក្នុងដំណើរការផលិតកម្ម។

**៥. ការបង្កើតបរិយាកាសការងារដែលប្រកបដោយភាពរីករាយ**

- **ការផ្តល់សេវាកម្មចំពោះបុគ្គលិក**: ក្រុមហ៊ុន Aprati Foods ផ្តល់នូវសេវាកម្មប្រកបដោយភាពទូលំទូលាយដែលអាចជួយបម្រើកម្រិតសុខភាព និងសុខុមាលភាពរបស់បុគ្គលិក។
- **ការជួយជំរុញឱ្យមានការចូលរួមធ្វើការព្រមគ្នា**: ក្រុមហ៊ុនជួយបង្កើតការចូលរួមជាមួយកម្មករនៅកន្លែងការងារក្នុងកំឡុងពេលធ្វើការជាមួយគ្នា។

ការគ្រប់គ្រង និងបែងចែកកម្លាំងពលកម្មរបស់ Aprati Foods គឺផ្តោតលើការសម្រេចការងារផលិតដោយប្រើប្រាស់បច្ចេកវិទ្យា និងវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាព។ ក្រុមហ៊ុនបានផ្តល់នូវការអភិវឌ្ឍជំនាញ និងភាពរីករាយក្នុងការងារប្រកបដោយការយកចិត្តទុកដាក់លើបុគ្គលិក ដើម្បីធានាការផលិតមានគុណភាពនៅកម្រិតល្អបំផុត។

### ឃ. ការគ្រប់គ្រងពេលវេលាក្នុងដំណើរការផលិត

ការគ្រប់គ្រងពេលវេលាផលិតស្ករគ្រាប់របស់ ក្រុមហ៊ុន Aprati Foods មានសារៈសំខាន់ណាស់ក្នុងការបង្កើតផលិតផលដែលមានគុណភាព និងការផ្តល់ជូនអតិថិជនក្នុងពេលវេលាដែលបានកំណត់។ នៅក្នុង វិស័យផលិតស្ករគ្រាប់ ក្រុមហ៊ុននឹងត្រូវការការគ្រប់គ្រងប្រព័ន្ធផលិតដូចជា សម្ភារៈ, ម៉ាស៊ីន, និងពេលវេលាដើម្បីធានាថាការផលិតពិតជាគ្រប់គ្រាន់ និងមានប្រសិទ្ធភាព។

#### ១. ការគ្រប់គ្រងការទទួលវត្ថុធាតុដើម (Raw Materials)

- ស្ករគ្រាប់ត្រូវការវត្ថុធាតុដើមដូចជា ស្ករ, ទឹក និងសារធាតុផ្សំផ្សេងៗ។ ក្រុមហ៊ុន Aprati Foods ត្រូវតែគ្រប់គ្រងការទិញវត្ថុធាតុដើមប្រកបដោយប្រសិទ្ធភាព ដើម្បីទទួលបានវត្ថុធាតុក្នុង កំឡុងពេលដែលត្រូវការតាមការកំណត់។
- ការកំណត់ស្តុក និងការបញ្ជាទិញវត្ថុធាតុដើមដូចជា ស្ករនិងគ្រឿងផ្សំផ្សេងៗគឺជាសកម្មភាពដ៏សំខាន់សម្រាប់ការកាត់បន្ថយពេលវេលា និងការពន្លឿនពេលក្នុងដំណើរការផលិត។

#### ២. ការរៀបចំកាលវិភាគផលិត

- ក្រុមហ៊ុន Aprati Foods អាចបង្កើតកាលវិភាគដែលកំណត់ពេលវេលាច្បាស់លាស់សម្រាប់ដំណើរការផលិតស្ករគ្រាប់ ដូចជាការចាក់ស្ករ, ការលាយ, ការបញ្ចប់ និងការកែច្នៃស្ករគ្រាប់បានគ្រប់គ្រាន់តាមស្តង់ដានៃគុណភាព។ កាលវិភាគនេះជាផ្នែកសំខាន់សម្រាប់ការប្រកួតប្រជែងជាមួយក្រុមហ៊ុនផ្សេងៗ ហើយការរៀបចំកាលវិភាគជាក់លាក់សម្រាប់ បង្កើតផលិតផលអាចជួយឱ្យសកម្មភាពបន្តទៅតាមការកំណត់នៃពេលវេលា។

#### ៣. ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការផលិត

- Automation និង Advanced Production Systems: ក្រុមហ៊ុន Aprati Foods ប្រើប្រាស់បច្ចេកវិទ្យា Automation ក្នុងដំណើរការផលិតដើម្បីបង្កើនប្រសិទ្ធភាព និងកាត់បន្ថយការប្រើប្រាស់ពេលវេលា។ ការប្រើប្រាស់ម៉ាស៊ីនស្វ័យប្រវត្តិជួយឱ្យសកម្មភាពផ្សេងៗក្នុងការផលិតធ្វើបានយ៉ាងល្អឥតខ្ចោះ។

#### ៤. ការបង្កើនចំណូលប្រកបដោយគុណភាព

- ក្រុមហ៊ុន Aprati Foods ត្រូវការគ្រប់គ្រងពេលវេលាផលិតស្ករគ្រាប់ដោយការត្រួតពិនិត្យការផលិតយ៉ាងខ្ជាប់ខ្ជួន ដើម្បីធានាថាស្ករគ្រាប់ដែលត្រូវផលិតមានគុណភាពខ្ពស់ និងមានស្តង់ដារដែលអតិថិជនអាចទំនុកចិត្តបាន។

#### ៥. ការត្រួតពិនិត្យស្តុក និងចំណាយ

- ការត្រួតពិនិត្យស្តុក និងសម្ភារៈផ្សេងៗត្រូវបានប្រើប្រាស់ជាដំណោះស្រាយដើម្បីរក្សា ប្រសិទ្ធភាព និងធានាបាននូវគុណភាពល្អ។
- ការអនុវត្តវិធីសាស្ត្រកំណត់ស្តុក និងការគ្រប់គ្រងការចំណាយជារឿងចាំបាច់ ដើម្បីទទួលបានលទ្ធផលល្អ និងផ្តល់ផលចំណេញសម្រាប់ក្រុមហ៊ុន។

### ៦. ការពិនិត្យគុណភាព និងផលិតផលសម្រេច

- ក្រុមហ៊ុន Aprati Foods ត្រូវតែមានប្រព័ន្ធត្រួតពិនិត្យគុណភាព ដែលមានប្រសិទ្ធភាព សម្រាប់ការត្រួតពិនិត្យស្តុកគ្រាប់បន្ទាប់ពីដំណើរការផលិត និងមុនពេលធ្វើការធ្វើការនាំចេញផលិតផលទៅកាន់អតិថិជន។
- ការត្រួតពិនិត្យគុណភាព ធ្វើឱ្យក្រុមហ៊ុនមានភាពជឿជាក់ពីផលិតផលដែលខ្លួននាំចេញទៅកាន់អតិថិជន។

## ង. ការគ្រប់គ្រងចំណាយឱ្យមានប្រសិទ្ធភាព

ការគ្រប់គ្រងចំណាយឱ្យមានប្រសិទ្ធភាពរបស់ក្រុមហ៊ុន Aprati Foods គឺជាការអនុវត្ត ដែលធ្វើឱ្យក្រុមហ៊ុនអាចទទួលបាននូវការផលិតជោគជ័យក្នុងតម្លៃសមរម្យ និងមានគុណភាពខ្ពស់។ ក្រុមហ៊ុនបានប្រើប្រាស់និន្នាការ និងបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាព ដើម្បីគ្រប់គ្រងចំណាយ និងធានាថាការចំណាយត្រូវតាមគោលដៅ និងតាមផែនការដែលបានកំណត់។ ខាងក្រោមនេះគឺជាចំណុចសំខាន់ៗដែល Aprati Foods ប្រើប្រាស់ក្នុងការគ្រប់គ្រងចំណាយៈ

### ១. ការត្រួតពិនិត្យ និងបន្ថយចំណាយក្នុងផលិតកម្ម

- **ការគ្រប់គ្រងវត្ថុធាតុដើម**: Aprati Foods បានបន្ថែមប្រព័ន្ធគ្រប់គ្រងវត្ថុធាតុដើមដើម្បីធានាថាក្រុមហ៊ុនបានប្រើប្រាស់វត្ថុធាតុដើមស្របតាមតម្រូវការផលិត។ ការត្រួតពិនិត្យតាមប្រព័ន្ធកុំព្យូទ័រនឹងអនុញ្ញាតឱ្យក្រុមហ៊ុនគ្រប់គ្រងវត្ថុធាតុដើមបានយ៉ាងស្រួល និងកាត់បន្ថយការចំណាយ។

### ២. ការប្រើប្រាស់បច្ចេកវិទ្យាជំនួយក្នុងផលិតកម្ម

- **ការប្រើប្រាស់បច្ចេកវិទ្យា**: ក្រុមហ៊ុន Aprati Foods បានប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងការផលិតស្តុកគ្រាប់ដែលជួយកាត់បន្ថយការប្រើប្រាស់ថាមពល។

### ៣. ការប្រមូលព័ត៌មាន និងវិភាគទិន្នន័យ

- **ការប្រមូលព័ត៌មានពីអ្នកផ្គត់ផ្គង់ និងការពិចារណាអំពីតម្លៃ**: Aprati Foods ប្រើប្រាស់ប្រព័ន្ធវិភាគទិន្នន័យឱ្យមានប្រសិទ្ធភាពដើម្បីវាយតម្លៃប្រភពផ្គត់ផ្គង់ និងការជ្រើសរើសអ្នកផ្គត់ផ្គង់ដែលផ្តល់ឱ្យមានតម្លៃទំនិញសមរម្យ។
- **ការប្រមូលព័ត៌មានពីអតិថិជន**: Aprati Foods ប្រើប្រាស់ប្រព័ន្ធវិភាគទិន្នន័យឱ្យមានប្រសិទ្ធភាពដើម្បីវាយតម្លៃអតិថិជន និងផ្តល់តម្លៃទំនិញសមរម្យ។ ជាក់ស្តែងក្រុមហ៊ុនបានប្រមូលព័ត៌មានទាក់ទិននឹងបញ្ហាសេដ្ឋកិច្ច ដែលជាមូលហេតុធ្វើឱ្យមានផលប៉ះពាល់ដល់ការថយចុះនៃប្រាក់ចំណូលសរុបរបស់អតិថិជន ដែលជាឬសគល់ធ្វើឱ្យអតិថិជនកាត់បន្ថយការចំណាយទៅលើផលិតផលដែលមិនចាំបាច់ នាំឱ្យការផ្គត់ផ្គង់ផលិតផលសម្រេចរបស់ក្រុមហ៊ុនមានការថយចុះ។

### ៤. ការត្រួតពិនិត្យចំណាយ និងវាយតម្លៃ

- **ការត្រួតពិនិត្យការចំណាយជាប្រចាំ**: Aprati Foods ប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យចំណាយសម្រាប់ប្រតិបត្តិការ និងដំណើរការផលិត។

- **ការបន្ថយការចំណាយ**: ក្រុមហ៊ុនធ្វើការវាយតម្លៃលើការចំណាយ ក្នុងការផលិត និងធ្វើការកែសម្រួលឱ្យកាន់តែប្រសើរលើប្រព័ន្ធគ្រប់គ្រងថវិកា ដើម្បីធានាថាពួកគេកំពុងអនុវត្តលើវិធីសាស្ត្រដែលមានប្រសិទ្ធភាពបំផុត។ ជាក់ស្តែក ក្នុងក្រុមហ៊ុនដោយសារតែមានការត្រួតពិនិត្យ និងកាត់បន្ថយចំណាយច្រើនពេករហូតដល់ពាក់ព័ន្ធនឹងការធ្វើទីផ្សារ ធ្វើឱ្យ Brand Awareness នៅមានកម្រិតទាបធ្វើឱ្យអ្នកប្រើប្រាស់មិនស្គាល់ម៉ាកផលិតផលរបស់ក្រុមហ៊ុន ទោះបីជាផលិតផលមានគុណភាព និងស្តង់ដាអន្តរជាតិ វាបានធ្វើឲ្យទំនិញមិនអាចពង្រីកទីផ្សារផលិតផលរបស់ខ្លួនបាន និងខ្វះការផ្សព្វផ្សាយអាចធ្វើឱ្យក្រុមហ៊ុនបាត់បង់អតិថិជនទៅឱ្យគូប្រកួតប្រជែង ដែលគ្រប់គ្រងទីផ្សារបានល្អជាងខ្លួន។

**៥. ការបង្កើនការប្រើប្រាស់ធនធាន**

- **ការប្រើប្រាស់ធនធានបច្ចេកទេសដើម្បីបង្កើនប្រសិទ្ធភាព**: ក្រុមហ៊ុនមានប្រព័ន្ធបច្ចេកទេសដើម្បីជួយក្នុងការគ្រប់គ្រងកម្លាំងពលកម្ម និងការប្រើប្រាស់ធនធានតិច។
- **ការបង្កើតស្តង់ដាថ្មីៗក្នុងការគ្រប់គ្រងសម្ភារៈ**: ក្រុមហ៊ុនផ្តោតសំខាន់លើការបង្កើតប្រព័ន្ធដែលអាចសន្សំសំចៃការប្រើប្រាស់សម្ភារៈ និងបញ្ចប់ការចំណាយមិនចាំបាច់។

ការគ្រប់គ្រងចំណាយឱ្យមានប្រសិទ្ធភាពនៅក្នុងក្រុមហ៊ុន Aprati Foods គឺជាការអនុវត្តន៍នៃប្រព័ន្ធគ្រប់គ្រង និងបច្ចេកវិទ្យាដែលមិនត្រឹមតែជួយបន្ថយការចំណាយ ប៉ុន្តែថែមទាំងធានាថាក្រុមហ៊ុនអាចសម្រេចបានការផលិតស្អារ និងផលិតផលដែលមានគុណភាពល្អក្នុងតម្លៃសមរម្យ។

## ៣.៣ អត្ថប្រយោជន៍នៃការគ្រប់គ្រងដំណើរការផលិតឱ្យមានប្រសិទ្ធភាព

ការគ្រប់គ្រងដំណើរការផលិតឱ្យមានប្រសិទ្ធភាពគឺ មានសារៈសំខាន់ណាស់សម្រាប់ធានាផលិតភាពប្រសិទ្ធភាពថវិកា និងការអភិវឌ្ឍប្រកបដោយចីរភាព។ ការគ្រប់គ្រងដំណើរផលិតកម្មបានត្រឹមត្រូវ បានបង្កើនប្រតិបត្តិការអាជីវកម្មការពេញចិត្តរបស់អតិថិជនកំណើនសេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍបរិស្ថាន។ អត្ថប្រយោជន៍នេះ អាចបែងចែកជា ៤ ផ្នែកសំខាន់ៗដូចជា៖

**ក. អត្ថប្រយោជន៍សម្រាប់ក្រុមហ៊ុន**

- **បន្ថយការចំណាយ៖** ប្រសិទ្ធភាពក្នុងដំណើរការផលិត ជួយឱ្យក្រុមហ៊ុន អាចប្រើប្រាស់ធនធានដូចជាកម្លាំងពលកម្ម វត្ថុធាតុដើម និងថាមពលបានយ៉ាងមានប្រសិទ្ធភាព។ វាជួយកាត់បន្ថយកាកសំណល់ ការបាត់បង់ និងការចំណាយពេលវេលា។
- **បង្កើនផលិតភាព៖** ដំណើរការផលិតដែលមានប្រសិទ្ធភាព អាចបង្កើនសមត្ថភាពផលិតក្នុងរយៈពេលខ្លីជាងមុន។ ក្រុមហ៊ុនអាចផលិតបានច្រើនជាងមុនដោយប្រើប្រាស់ធនធានដដែល ឬទាបជាងមុន។ ការប្រើប្រាស់បច្ចេកវិទ្យា ដូចជា ម៉ាស៊ីនស្វ័យប្រវត្តិ ឬប្រព័ន្ធគ្រប់គ្រង ERP មានឥទ្ធិពលក្នុងការបង្កើនផលិតភាពខ្លាំង។
- **កែលម្អគុណភាពផលិតផល៖** ដំណើរការដែលបានបង្កើតដោយមានប្រសិទ្ធភាព អាចផ្តល់ផលិតផលដែលមានគុណភាពខ្ពស់ ប្រកបដោយស្ថិរភាព និងគ្មានកំហុស។ វាធានាថាអតិថិជន

- ទទួលបានផលិតផលដែលសមនឹងតម្លៃ។ ក្រុមហ៊ុនអាចបង្កើនភាពជឿជាក់នៃអតិថិជនលើម៉ាករបស់ខ្លួន។
- **បង្កើនការប្រកួតប្រជែង៖** នៅក្នុងទីផ្សារដែលមានការប្រកួតប្រជែងខ្លាំង ក្រុមហ៊ុនដែលមានការផលិតប្រកបដោយប្រសិទ្ធភាពអាចផ្តល់ផលិតផលល្អក្នុងតម្លៃទាបជាងគូប្រកួត។ វាជាជំហានសំខាន់សម្រាប់ការរក្សាទីតាំងក្នុងទីផ្សារ និងទាក់ទាញអតិថិជនថ្មីៗ។
- **បង្កើនប្រាក់ចំណូល៖** ប្រសិទ្ធភាពនាំឱ្យផលិតផលចេញទៅទីផ្សារបានច្រើនជាងមុន ជួយឱ្យក្រុមហ៊ុនលក់បានច្រើន និងទទួលបានប្រាក់ចំណូលកើនឡើង។
- **ការពង្រីកទីផ្សារ៖** ដោយមានលទ្ធភាពផលិតខ្ពស់ និងផលិតផលមានគុណភាព ក្រុមហ៊ុនអាចពង្រីកការលក់ទៅទីផ្សារថ្មីៗ មិនថាជាផ្នែកក្នុងប្រទេសឬបរទេស។ ប្រសិទ្ធភាពផ្តល់នូវឱកាសសម្រាប់ការពង្រីកទីផ្សារយ៉ាងទូលំទូលាយ។

**ខ. អត្ថប្រយោជន៍សម្រាប់អតិថិជន**

- **ផលិតផលមានគុណភាពខ្ពស់៖** អតិថិជនទទួលបានផលិតផលដែលមានគុណភាព ប្រើបានយូរ មានសុវត្ថិភាព និងងាយស្រួលប្រើ។
- **តម្លៃសមរម្យ៖** ព្រោះក្រុមហ៊ុនកាត់បន្ថយការចំណាយក្នុងផលិតកម្ម តម្លៃលក់នឹងក្លាយជាសមរម្យសម្រាប់អតិថិជន។ វាជួយឱ្យអតិថិជនអាចទិញបាន និងគាំទ្រផលិតផលក្នុងរយៈពេលវែង។
- **ការចែកចាយរហ័ស៖** ក្រុមហ៊ុនដែលមានប្រសិទ្ធភាពអាចបំពេញការបញ្ជាទិញបានយ៉ាងឆាប់រហ័ស។ វាជួយបំពេញតម្រូវការអតិថិជនតាមពេលវេលា និងបង្កើនភាពពេញចិត្តដល់អតិថិជន។
- **ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព៖** ផលិតផលដែលផលិតប្រកបដោយប្រសិទ្ធភាពខ្ពស់ តែងមានរចនាបទ ឬមុខងារដែលងាយស្រួលប្រើប្រាស់។ អតិថិជននឹងទទួលបានបទពិសោធន៍ប្រើប្រាស់ល្អប្រសើរជាងមុន។
- **ការលម្អលើសេវាកម្ម៖** ប្រសិទ្ធភាពក្នុងដំណើរការផលិតនាំឱ្យក្រុមហ៊ុនមានការប្រព្រឹត្តទៅល្អក្នុងគ្រប់ផ្នែក រួមទាំងផ្នែកសេវាកម្ម។ ការឆ្លើយតបលឿន សេវាផ្គត់ផ្គង់ល្អ និងការផ្តល់ព័ត៌មានត្រឹមត្រូវបន្ថែមភាពពេញចិត្តរបស់អតិថិជន។
- **កំណត់តម្លៃតាមតម្រូវការអតិថិជន៖** ការផលិតប្រកបដោយប្រសិទ្ធភាពអាចអនុញ្ញាតឱ្យក្រុមហ៊ុនមានភាពបត់បែនក្នុងការកំណត់តម្លៃផលិតផលឬសេវាកម្ម ដើម្បីឆ្លើយតបទៅនឹងតម្រូវការពិសេសរបស់អតិថិជន។

**គ. អត្ថប្រយោជន៍សម្រាប់សង្គមជាតិ**

- **ការបង្កើតការងារ៖** ប្រសិទ្ធភាពក្នុងដំណើរការផលិតធ្វើឱ្យ ក្រុមហ៊ុនអាចពង្រីកការដំណើរការ និងការផលិតបានយ៉ាងលឿន។ ជាក់ស្តែង វាជួយកាត់បន្ថយអត្រាការខ្វះការងារ និងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជនក្នុងសង្គម។

- **កំណើនសេដ្ឋកិច្ច៖** ការអភិវឌ្ឍផលិតកម្មរបស់សហគ្រាស នាំឱ្យមានការចំណាយបន្ថែមលើធនធាន ការទិញវត្ថុធាតុដើម និងសេវាកម្មផ្សេងៗ។ វាជួយបង្កើនចំណូលរបស់បុគ្គល និងរដ្ឋាភិបាល ដោយធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើនបន្ថែមទៀត។
- **ការនាំចេញកាន់តែច្រើន៖** ដោយមានផលិតផលដែលមានគុណភាព និងតម្លៃសមរម្យ ក្រុមហ៊ុនអាចនាំចេញទៅទីផ្សារអន្តរជាតិនៅក្រៅប្រទេសបាន។ វាជួយបង្កើនចំណូលរដ្ឋ និងបង្កើនវិនិយោគិនបរទេសផងដែរ។
- **ជំរុញការអភិវឌ្ឍវិស័យទូរគមនាគមន៍៖** ការផលិតដែលប្រកបដោយប្រសិទ្ធភាពតែងតែរួមបញ្ចូលបច្ចេកវិទ្យាថ្មីៗ ដូចជា AI និងគ្រប់គ្រងតាម Cloud។ វាជំរុញឱ្យវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាកុំព្យូទ័ររីកចម្រើន។
- **ការចូលរួមសេដ្ឋកិច្ចពិភពលោក៖** ការបង្កើតប្រព័ន្ធផលិតភាព ប្រកបដោយស្តង់ដារអន្តរជាតិ អាចធ្វើឱ្យប្រទេសជាតិចូលរួមក្នុងបណ្តាញផលិតកម្មសកល។ វានាំឱ្យប្រទេសទាក់ទាញវិនិយោគបរទេស និងរួមចំណែកក្នុងការអភិវឌ្ឍជាតិ។

**ឃ. អត្ថប្រយោជន៍សម្រាប់បរិស្ថាន**

- **កាត់បន្ថយកាកសំណល់៖** ដំណើរការផលិតដែលមានប្រសិទ្ធភាពតែងតែមានការគិតគូរយ៉ាងម៉ត់ចត់អំពីការប្រើប្រាស់ធនធាន ដូច្នេះវាធ្វើឱ្យកាកសំណល់ពីផលិតកម្មបន្ថយមកតិច និងងាយគ្រប់គ្រងបានត្រឹមត្រូវ។ ក្រុមហ៊ុនអាចបង្កើតប្រព័ន្ធ Reuse និង Recycle ឬផលិតផលដែលងាយលាយ។
- **ប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព៖** ការផលិតឆ្ពោះទៅរក ប្រសិទ្ធភាពនាំឱ្យមានការប្រើប្រាស់ធនធានធម្មជាតិ ដូចជាទឹក ថាមពល និងវត្ថុធាតុដើមបានយ៉ាងប្រកបដោយការយកចិត្តទុកដាក់ និងកម្រិតតិចតួចបំផុត។
- **កាត់បន្ថយការបំពុល៖** ក្រុមហ៊ុនដែលគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនឹងពិចារណាពីចំណុចសំខាន់នៃការបញ្ចេញផ្សែងពុល ការបញ្ចេញទឹកស្អុយ និងសារធាតុពុលផ្សេងៗ។ វាធ្វើឱ្យការបំពុលបរិស្ថានថយចុះ។
- **ប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព៖** ដំណើរការផលិតដែលមានប្រសិទ្ធភាព វាបានជួយទៅដល់ការប្រើប្រាស់ថាមពលអគ្គិសនី ឬថាមពលឥន្ធនៈសន្សំសំចៃបានច្រើនក្នុងការជួយរក្សាបានដល់បរិស្ថាន។
- **ការអភិវឌ្ឍបច្ចេកវិទ្យាដែលកាត់បន្ថយ ការប្រើប្រាស់ធនធានធម្មជាតិ៖** ការអភិវឌ្ឍផលិតកម្មប្រកបដោយបច្ចេកវិទ្យា Smart Manufacturing ឬ Green Technology អាចជួយកាត់បន្ថយការប្រើប្រាស់ធនធាន ដូចជាដី ទឹក ថ្ម និងព្រៃឈើជាដើម។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគលើចំណុចខ្លាំង

បន្ទាប់ពីបានចុះកម្មសិក្សានៅក្រុមហ៊ុនរួចមក ក្រុមយើងខ្ញុំបានសង្កេតឃើញនៅចំណុចខ្លាំងមួយចំនួនរបស់ក្រុមហ៊ុន Aprati Foods មានដូចខាងក្រោម៖

- ក្រុមហ៊ុននេះមានប្រព័ន្ធគ្រប់គ្រងស្តង់ដារបានល្អ ផ្នែកគុណភាព និងអនាម័យតាមបែបស្តង់ដារអន្តរជាតិ។ Aprati Foods ជាក្រុមហ៊ុនដំបូងគេនៅកម្ពុជា ដែលផលិតស្ករគ្រាប់ដោយប្រើស្តង់ដារ BRCGS (Brand Reputation Compliance Global Standards ) ដែលទទួលស្គាល់ជាសកល។ ក្រុមហ៊ុនក៏មានវិញ្ញាបនបត្រ SA 8000 (Social accountability Standard) សម្រាប់ការអនុវត្តស្តង់ដារការងារយ៉ាងមានសុចរិតភាព។
- ក្រុមហ៊ុនមានទិសដៅ និងយុទ្ធសាស្ត្រច្បាស់លាស់ក្នុងការអនុវត្តផែនការ ក្នុងការប្រើប្រាស់ធនធានដែលក្រុមហ៊ុនមានដូចជា មនុស្ស ថវិកា ពេលវេលា ប្រកបដោយប្រសិទ្ធភាព។
- ផលិតផលនៅក្នុងក្រុមហ៊ុនមានច្រើនប្រភេទ ច្រើនរសជាតិ ថែមទាំងមានតម្លៃសមរម្យសម្រាប់បំពេញនូវតម្រូវការរបស់អតិថិជនបានគ្រប់ឋានៈ មិនថាមាន ឬក្រក៏អាចមានលទ្ធភាពទិញស្ករគ្រាប់របស់ក្រុមហ៊ុន Aprati Foods បានដែរ។
- ទំហំទីផ្សារចែកចាយ៖

+ ទីផ្សារក្នុងស្រុក៖ បានចែកចាយទូទាំងរាជធានីខេត្ត ក្នុងប្រទេសកម្ពុជា។
+ ទីផ្សារក្រៅស្រុក៖ Aprati Foods មិនត្រឹមតែផ្គត់ផ្គង់ផលិតផលនៅក្នុងប្រទេសកម្ពុជានោះទេ ប៉ុន្តែថែមទាំងនាំចេញទៅកាន់ប្រទេសជាច្រើនដូចជាសហរដ្ឋអាមេរិក កូរ៉េ ជប៉ុន និងប្រទេសផ្សេងទៀត។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ក្រោយពីបានសង្កេត និងវិភាគនូវចំណុចខ្លាំងរួចមក ក្រុមយើងខ្ញុំក៏បានរកឃើញនូវចំណុចខ្សោយមួយចំនួនដូចខាងក្រោម៖

- ក្រុមហ៊ុននៅមានកម្រិតនៅក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗដូចជា ERP system, automation machine ឬ barcode system អាចជួយបង្កើនល្បឿននៃការផលិត និងកាត់បន្ថយកម្លាំងពលកម្ម។
- Brand Awareness នៅមានកម្រិតទាបមិនទាន់ស្គាល់ទូលំទូលាយ ទោះបីជាផលិតផលមានគុណភាព និងស្តង់ដារអន្តរជាតិ តែការផ្សព្វផ្សាយ ធ្វើទីផ្សារនៅតិចជាងម៉ាកមួយចំនួនដែលនាំចូល។
- ការរំខានខាងសេដ្ឋកិច្ច អាចប៉ះពាល់ដល់បណ្តាញផ្គត់ផ្គង់ដូចជាបញ្ហាកសិកម្ម និងការធ្លាក់ចុះនៃប្រាក់ចំណូលសរុបរបស់អតិថិជន (ក្នុងស្ថានភាពវិបត្តិសេដ្ឋកិច្ច) ដែលអតិថិជនអាចកាត់បន្ថយការទិញផលិតផលបន្ថែមមិនចាំបាច់។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវ និងស្រង់យកទិន្នន័យតាមរយៈការសាកសួរ និងការប្រមូលទិន្នន័យតាមប្រព័ន្ធអ៊ិនធឺណិតនៃប្រធានបទ *"ប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិត"* រួចមក ក្រុមយើងខ្ញុំបានផ្តោតលើការសិក្សា និងវិភាគអំពីប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិតរបស់ក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា) ដោយប្រើវិធីសាស្ត្រស្រាវជ្រាវតាមបែបគុណវិស័យ និងប្រមូលទិន្នន័យបន្ទាប់បន្សំ។ តាមរយៈការវិភាគឯកសារ និងសម្ភាសន៍ផ្ទាល់ ក្រុមយើងខ្ញុំបានរកឃើញថា ក្រុមហ៊ុនមានការគ្រប់គ្រងយ៉ាងច្បាស់លាស់និង ការចាត់ចែងនៅគ្រប់ដំណាក់កាលនៃដំណើរការផលិត ចាប់ពីការរៀបចំវត្ថុធាតុដើម ការផលិត ការវេចខ្ចប់ ការត្រួតពិនិត្យគុណភាព រហូតដល់ការរក្សាទុកផលិតផលសម្រេច។ ការគ្រប់គ្រងទាំងនេះបានជួយឱ្យក្រុមហ៊ុនអាចផលិតបានច្រើន មានគុណភាពខ្ពស់ និងទាន់ពេលវេលាតាមការកំណត់។

បន្ថែមពីនេះ ក្រុមហ៊ុនក៏មានយុទ្ធសាស្ត្រល្អប្រសើរដូចជា ការធ្វើផែនការច្បាស់លាស់ ការបែងចែកកម្លាំងពលកម្មឱ្យបានត្រឹមត្រូវ ការគ្រប់គ្រងវត្ថុធាតុដើមឱ្យបានប្រកបដោយប្រសិទ្ធភាព ការកំណត់ពេលវេលាដោយមានតុល្យភាព និងការត្រួតពិនិត្យចំណាយឱ្យសមរម្យ។ យុទ្ធសាស្ត្រទាំងនេះមិនត្រឹមតែជួយកាត់បន្ថយកំហុសក្នុងដំណើរការផលិតប៉ុណ្ណោះទេ ប៉ុន្តែសម្រួលការធ្វើការជាក្រុម បង្កើនការរួមចំណែកពីបុគ្គលិក និងធានាការអភិវឌ្ឍដោយឆាប់រហ័ស។ កត្តាទាំងនេះ ទាំងអស់បង្ហាញថាក្រុមហ៊ុនបានគ្រប់គ្រងការផលិតដោយគោរពទៅតាមបច្ចេកទេស និងគោលការណ៍គ្រប់គ្រងទំនើបមានគុណភាព និងមានចក្ខុវិស័យយូរអង្វែង។

ចុងបញ្ចប់ ការសិក្សារបស់យើងបានបញ្ជាក់ថា ប្រសិទ្ធភាពនៃការគ្រប់គ្រងដំណើរការផលិតគឺជាគន្លឹះសំខាន់មួយសម្រាប់ការរីកចម្រើនរបស់អង្គភាពឧស្សាហកម្ម។ វាជួយក្រុមហ៊ុនមិនត្រឹមតែរក្សាភាពប្រកួតប្រជែងនាពេលបច្ចុប្បន្នទេ ប៉ុន្តែរួមចំណែកសំខាន់ក្នុងការរក្សាគុណភាពផលិតផល ឆ្លើយតបតាមតម្រូវការរបស់ទីផ្សារជាតិ និងអន្តរជាតិ។ ដូចនេះ ការយកចិត្តទុកដាក់លើការគ្រប់គ្រងដំណើរការផលិតឱ្យបានល្អ គឺជាកត្តាដែលមិនអាចមើលរំលងបានសម្រាប់ក្រុមហ៊ុនដែលចង់ឈានមុខគេក្នុងវិស័យផលិតកម្ម។

## ៥.២ ការផ្តល់អនុសាសន៍

ដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវ ទោះបីក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា) មានការគ្រប់គ្រងដំណើរការផលិតបានល្អហើយក្តី តែយ៉ាងណាក៏ដោយក៏នៅតែមានកន្លែងដែលគួរអភិវឌ្ឍបន្ថែមនៅក្នុងចំណុចមួយចំនួនផងដែរ។ ដូច្នេះខាងក្រោមនេះគឺជាការផ្តល់អនុសាសន៍ ដើម្បីជួយ កែលម្អ និងបន្តការរីកចម្រើនក្នុងការគ្រប់គ្រងដំណើរការផលិតឱ្យកាន់តែមានប្រសិទ្ធភាពមានដូចខាងក្រោម៖

- ក្រុមហ៊ុនគួរតែមានការនាំបច្ចេកវិទ្យាថ្មីៗដូចជា ERP system, automation machine ឬ barcode system អាចជួយបង្កើនល្បឿននៃការផលិត និងកាត់បន្ថយកម្លាំងពលកម្មដោយខ្លួនឯង វាក៏ជួយកាត់បន្ថយកំហុសបច្ចេកទេសក្នុងដំណើរការផលិតផងដែរ។

- ក្រុមហ៊ុនគួរតែបង្កើនការផ្សព្វផ្សាយអំពីផលិតផលរបស់ខ្លួន ដើម្បីទាក់ទាញអតិថិជនបន្ថែម មិនថាតែនៅក្នុងស្រុក និងក្រៅប្រទេស ដើម្បីផ្សព្វផ្សាយអំពី Branding របស់ខ្លួន។
- ក្រុមហ៊ុនគួរតែត្រួតពិនិត្យ និងតាមដានជាប្រចាំអំពីបញ្ហាសេដ្ឋកិច្ច ចំណង់ចំណូលចិត្តរបស់អតិថិជន, ទីផ្សារសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញផលិតផលសម្រេច។

# ឯកសារយោង


1. វិគីនុក្រម. (២០១៩). *ប្រសិទ្ធភាព.* Retrieved May, 13 2025, from https://km.wiktionary.org/wiki/ប្រសិទ្ធភាព
2. វិទ្យាស្ថានវ៉ាន់ដា. (២០២៣). *មូលដ្ឋានគ្រឹះនៃការគ្រប់គ្រង.* ទំព័រទី២៥
3. FUSU Digital Press. Pindur, Rogers, and Kim. (2020). *ប្រវត្តិប្រសិទ្ធភាព និងការគ្រប់គ្រង.* Retrieved May, 13 2025, from https://fhsu.pressbooks.pub/management/chapter/the-history-of-management/
4. Intelligent Economist. Prateek Agarwal. (2025, April 7) *ទ្រឹស្តីនៃប្រសិទ្ធភាព.* Retrieved May, 13 2025, from https://www.intelligenteconomist.com/theory-of-efficiency/
5. CFI. CIF Team. (2025). *ទ្រឹស្តីនៃការគ្រប់គ្រង.* Retrieved May, 13 2025, from https://corporatefinanceinstitute.com/resources/management/management-theories/
6. Asana. Julia Martins. (2025, May 19). *ប្រភេទនៃការគ្រប់គ្រង.* Retrieved June, 15 2025, from https://asana.com/resources/management-styles
7. វិគីនុក្រម. (2016, June 5). *យុទ្ធសាស្ត្រ.* Retrieved July, 15 2025, from https://km.wiktionary.org/ *យុទ្ធសាស្ត្រ*
8. Strategyskills. Rich Horwath. (2020, July 1) *ទ្រឹស្តីពាក់ព័ន្ធនឹងយុទ្ធសាស្ត្រ.* Retrieved May, 15 2025, from https://www.strategyskills.com/the-origin-of-strategy/
9. MILITARY STRATEGY MAGAZINE. M.L.R. Smith. (2022). *ទ្រឹស្តីនៃយុទ្ធសាស្ត្រ* .Retrieved July, 15 2025, from https://www.militarystrategymagazine.com/article/on-efficacy-a-beginners-guide-to-strategic-theory/
10. GeeksforGeeks. (225, July 23). *ប្រភេទយុទ្ធសាស្ត្រនៃការគ្រប់គ្រង.* Retrieved August, 15 2025, from https://www.geeksforgeeks.org/business-studies/types-of-strategies/
11. ANT. (2018). *និយមន័យការផលិត.* Retrieved August, 15 2025, from http://dict.antkh.com/dictionaries/production.aspx
12. Interdisciplinary Professional Programs. (2024, November 14). *ប្រវត្តិនៃការផលិត.* Retrieved August, 16 2025, from https://interpro.wisc.edu/the-history-and-evolution-of-manufacturing
13. GeeksforGeeks. (2024, February 29). *លក្ខណៈនៃការគ្រប់គ្រង.* Retrieved August, 15 2025, from https://www.geeksforgeeks.org/production-function-meaning-features-and-types/
14. Makers Row. Shruti Ghosh. (2024, July 19). *អត្ថប្រយោជន៍នៃការផលិត.* Retrieved August, 30 2025, from https://makersrow.com/blog/top-10-benefits-of-keeping-your-manufacturing-local/

# ឧបសម្ព័ន្ធ




រូបភាពនៃក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)








សកម្មភាពរបស់ក្រុមនិស្សិតពេលចុះកម្មសិក្សានៅក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)

# ឯកសារសំណើសុំការអនុញ្ញាតឱ្យនិស្សិតចុះកម្មសិក្សាស្រាវជ្រាវនៅក្រុមហ៊ុន អេប្រាធី ហ្វ៊ូដ (ខេមបូឌា)



ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
ល.រ: ៤១២.០៣/វវដ
២៥

**នាយកវិទ្យាស្ថាន វ៉ាន់ដា**
**គោរពជូន**
**លោក Benjamin PEDRO ជា Technical Fellow**
**ក្រុមហ៊ុន Aprati Foods (Cambodia)**

**កម្មវត្ថុ៖** សំណើសុំការអនុញ្ញាតឱ្យនិស្សិតចំនួន ៥នាក់ ចុះកម្មសិក្សាស្រាវជ្រាវនៅ ក្រុមហ៊ុន Aprati Foods (Cambodia) លើប្រធានបទ «ភាពនៃការគ្រប់គ្រងដំណើរការផលិតរបស់ក្រុមហ៊ុន អេប្រាធី ហ៊្វូដ (ខេមបូឌា)»។

សេចក្ដីដូចចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន លោក Benjamin PEDRO មេត្តាជ្រាបថា និស្សិតដែលបានទទួលការបណ្ដុះបណ្ដាល នៅវិទ្យាស្ថាន វ៉ាន់ដាមានទិសដៅចាំបាច់ក្នុងការបង្កើនចំណេះដឹងរបស់ខ្លួន ដោយផ្សារភ្ជាប់រវាងទ្រឹស្ដីទៅនឹងការអនុវត្តន៍ជាក់ស្ដែង ព្រមទាំងបទពិសោធន៍ជាមូលដ្ឋានគ្រឹះសម្រាប់ការសរសេរនិក្ខេបបទបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២ ក្នុងឆ្នាំសិក្សា ២០២៤-២០២៥ នេះ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក Benjamin PEDRO មេត្តាពិនិត្យ និងអនុញ្ញាតឱ្យនិស្សិត វិទ្យាស្ថានយើងខ្ញុំ បានសិក្សាស្វែងយល់ពីប្រធានបទខាងលើដោយក្តីអនុគ្រោះ។

សូមលោក Benjamin PEDRO ទទួលនូវការគោរពរាប់អានពីខ្ញុំបាទ។

ថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៥
**នាយកវិទ្យាស្ថាន**

បណ្ឌិត **ហេង_វ៉ាន់ដា**

សូមជូនភ្ជាប់មកជាមួយនូវ៖
-បញ្ជីឈ្មោះនិស្សិតចុះកម្មសិក្សា ១ច្បាប់

អាសយដ្ឋាន: អគារលេខ ២១៦-២១៨ មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
Address: Nº216-218, Mao Tse Toung Blvd., Sangkat Tumnub Tuek, Khan Boeng Keng Kong, Phnom Penh.
ទូរស័ព្ទ: ០២៣ ២១៣ ៥៦៣ ទូរស័ព្ទដៃ: ០៦៩ ៥៧០ ៥៦១ ហ្វេសប៊ុក: VANDA Institute អ៊ីមែល: vanda@camnet.com.kh គេហទំព័រ: www.vanda.edu.kh
Tel: 023 213 563, H/P:069 570 561, Facebook: VANDA Institute., E-mail: vanda@camnet.com.kh. Website: www.vanda.edu.kh



ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
ល.រ: ៤១៣.០៣/វវដ
២៥

**បញ្ជីឈ្មោះនិស្សិតដែលស្នើសុំចុះកម្មសិក្សា**

| ល.រ | អត្តលេខ | គោត្តនាម និងនាម | ភេទ | លេខទូរស័ព្ទ |
|---|---|---|---|---|
| ១ | B22/2023 | នុន សុម៉ារត្តី | ស្រី | ០៩៦ ៥៦៥ ៥០៤ ៣ |
| ២ | B22/2029 | វន ស្រីណាត | ស្រី | ០៧០ ៥១២ ៣២៣ |
| ៣ | B22/2024 | ទី សុភ័ក្ត្រវត្តី | ស្រី | ០៩៦ ៤០៦ ១០៧ ៨ |
| ៤ | B22/1117 | រិទ្ធ ជាកាំង | ប្រុស | ០១០ ៩១៩ ១១៥ |
| ៥ | B22/2053 | វណ្ណ វីរៈយុទ្ធ | ប្រុស | ០៨៧ ៩០១ ៨៨៤ |

សរុបបញ្ជីឈ្មោះត្រឹមចំនួន ៥នាក់ (ប្រាំនាក់)។

ថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៥
**នាយកវិទ្យាស្ថាន**

បណ្ឌិត **ហេង_វ៉ាន់ដា**

អាសយដ្ឋាន: អគារលេខ ២១៦-២១៨ មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
Address: Nº216-218, Mao Tse Toung Blvd., Sangkat Tumnub Tuek, Khan Boeng Keng Kong, Phnom Penh.
ទូរស័ព្ទ: ០២៣ ២១៣ ៥៦៣ ទូរស័ព្ទដៃ: ០៦៩ ៥៧០ ៥៦១ ហ្វេសប៊ុក: VANDA Institute អ៊ីមែល: vanda@camnet.com.kh គេហទំព័រ: www.vanda.edu.kh
Tel: 023 213 563, H/P:069 570 561, Facebook: VANDA Institute., E-mail: vanda@camnet.com.kh. Website: www.vanda.edu.kh